# កម្ពុជាក្រោម

Kampuchea-Krom

លេខ ៨១ ឆ្នាំទី ០៨ KKFN/81/2011 ខែ មិថុនា គ.ស. ២០១១ - ព.ស. ២៥៥៥


# សាខាសហព័ន្ធខ្មែរកម្ពុជាក្រោម នៅប្រទេសបារាំង រំលឹកខួប៦២ឆ្នាំ ថ្ងៃបារាំងកាត់ទឹកដីកម្ពុជាក្រោម ឱ្យទៅយួន



ថ្នាក់ដឹកនាំ និងព្រះសង្ឃ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងពិធីរំលឹកខួបទិវាបារាំងកាត់ទឹកដីកម្ពុជាក្រោមឲ្យយួន នៅសាធារណរដ្ឋបារាំង

ថ្ងៃទី០៤ ខែមិថុនា គឺជាខួបទី៦២ឆ្នាំ ដែលព្រះរាជាណាចក្រកម្ពុជា បាត់បង់ទឹកដីខ្មែរក្រោមទៅឲ្យវៀតណាម។ សហព័ន្ធខ្មែរកម្ពុជាក្រោម បានរៀបចំពិធីរំឭកខួបនេះហូរហែ ជារៀងរាល់ឆ្នាំ ដូចជានៅសហរដ្ឋអាមេរិក កាណាដា ស្វីស បារាំង និងនៅតាមបណ្តាប្រទេសនានាជាច្រើនទៀត។ នៅថ្ងៃនេះដែរ ១៩ មិថុនា សាខាសហព័ន្ធខ្មែរ កម្ពុជាក្រោម នៅខេត្ត Toulouse ប្រទេសបារាំង បានរៀបចំ ធ្វើពិធីរំឭកខួបទី៦២ឆ្នាំ សោកនាដកម្មនៃការបាត់បង់ទឹកដីខ្មែរកម្ពុជាក្រោម ទៅឲ្យវៀតណាមនេះផងដែរ ដោយមានការចូលរួមពីព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរ ខ្មែរក្រោមជាង១០០អង្គ និងរូប មកពីប្រទេសកាណាដា ស្វីស និងមកពីបណ្តាខេត្តនានាក្នុងប្រទេសបារាំង។ លោក **ឡឹម វ៉ាំងគៀង** ដែលជាប្រធានសាខាសហព័ន្ធខ្មែរកម្ពុជាក្រោម នៅទីក្រុង Toulouse និងជាអ្នកចាត់ចែងពិធីបុណ្យបានថ្លែងថា *"បាទ! ថ្ងៃនេះ សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំខេត្ត Toulouse ស្រុកបារាំងនេះ បានរៀបចំទិវាមួយឲ្យឈ្មោះថា ទិវារំឭកថ្ងៃបាត់បង់ទឹកដីខ្មែរកម្ពុជាក្រោម ដោយក្នុងគោលបំណង៣ គឺ៖ ទី១ ដើម្បីសំដែងនូវសោកនាដកម្ម របស់ជនជាតិខ្មែរកម្ពុជាក្រោម និងការសោកស្តាយការបាត់បង់ទឹកដីដូនតាយើង។ ទី២ទៀត ដើម្បីនឹងដាស់ស្មារតីឲ្យចងចាំដល់កុលបុត្រខ្មែររបស់យើងគ្រប់ជំនាន់ ឲ្យដឹងយល់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន ដើម្បីនឹងជៀសវាង។ ទី៣ គឺដើម្បីបង្ហាញទាក់ទាញនូវមតិអន្តរជាតិដែលជាអ្នកស្រឡាញ់យុត្តិធម៌ ស្រឡាញ់សច្ចធម៌ ជួយគាំទ្រដល់សហព័ន្ធខ្មែរកម្ពុជាក្រោម*

តទៅទំព័រ ៤

## មាតិការឿង


សាខាសហព័ន្ធខ្មែរកម្ពុជាក្រោម ........................ ១
វិចារណកថា ........................ ២
សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស ........ ៨
មេធាវីជនជាតិសិង្ហបុរី ........................ ១០
អាជ្ញាធរយួនបំបិទសិទ្ធិសេរីភាព ........................ ១១
រដ្ឋអំណាចយួនបង្ខំខ្មែរក្រោម ........................ ១៣
ព្រះមហាក្សត្រខ្មែរអំពាវនាវសុំឲ្យបារាំង .......... ១៥
ខ្មែរកម្ពុជាក្រោមជានរណា? (ត) ........................ ១៧
ទិវាបុណ្យឯករាជ្យ នៃសហរដ្ឋអាមេរិក ............ ២២
លិខិតរបស់អង្គការ សមាគម ........................ ២៤
ទំនៀមធ្វើស្រែនៅកម្ពុជាក្រោម ........................ ២៦
ការចាប់លោក ថៅ ហេន ញាត់ក្នុងគុក ............ ២៩
ខ្មែរឡើងទ្រើង ........................ ៣១
យួន ........................ ៣១


ទីស្នាក់ការ ÷ P.O. Box 0193, Pennsauken, NJ 08110, USA, Tel: (856) 655-3838, E-mail: info.dep@khmerkrom.org

# ស្អែក គឺថ្ងៃនេះ




លោកអាលប៊ឺតអែនស្តែន បានទុកពាក្យស្លោក ដូចតទៅ៖ "រៀនសូត្រពីអតីតកាល, រស់នៅ ថ្ងៃនេះ, សង្ឃឹមថ្ងៃស្អែក។ រឿងសំខាន់ គឺកុំឈប់លើកជាសំណួរ"។ "Learn from yesterday, live for today, hope for tomorrow. The important thing is not to stop questioning." Albert Einstein

- តើខ្មែរក្រោម (ឬខ្មែរទូទៅ)បានរៀនចេះ អ្វីខ្លះពីអតីតកាល?
- តើយើងត្រូវរស់នៅយ៉ាងដូចម្តេច?
- តើយើងសង្ឃឹមលើអ្វីនៅថ្ងៃស្អែក?

ក្នុងនាមជាជនខ្មែរក្រោម យើងសូមសាកល្បងឆ្លើយនឹងសំណួរនេះដូចតទៅ៖ តើខ្មែរក្រោម (ឬខ្មែរទូទៅ) បានរៀនចេះអ្វីខ្លះពីអតីតកាល? អ្នកដឹកនាំប្រវត្តិសាស្ត្ររបស់យួន ឈ្មោះ ហូជីមិញ នៅពេលធ្វើសេចក្តីប្រកាសឯករាជ្យពីប្រទេសបារាំង នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ បានដកស្រង់យកសំដីរបស់ប្រធានាធិបតី នៃសហរដ្ឋអាមេរិក **ថូមាស់ ជែហ្វឺសុន** មកសូត្រថា៖ «មនុស្សទាំងអស់ត្រូវបានបង្កើតមកស្មើភាពគ្នា» ហើយជននេះ ក៏បានលើកយកពាក្យពីប្រកាសអំពីសិទ្ធិមនុស្ស របស់ប្រទេសបារាំងមកនិយាយ គឺ «មនុស្សទាំងអស់ កើតមកដោយសេរី និងមានសិទ្ធិស្មើគ្នា ហើយត្រូវតែនៅជាសេរី និងមានសិទ្ធិស្មើគ្នាជាដរាប នេះជាការពិតដែលមិនអាចប្រកែកបាន។ នៅពេលដែលត្រូវការសិទ្ធិ និងសេរីភាព យួនបានយកពាក្យល្អៗនេះមកស្រែក ប៉ុន្តែទន្ទឹមនោះ យើងជាខ្មែរក្រោមទាំងអស់គ្នា កុំថាដល់បានទទួលពន្លឺមួយចម្រៀកនៃសិទ្ធិសេរីភាពនោះ កើតមកដឹងក្តីក្នុងសញ្ជាតិជាខ្មែរនៅលើទឹកដី មតិក កេរដូនតាយើង បែរជាទទួលបាននូវការត្រួតត្រាផ្តាច់ការរំលាយពូជសាសន៍ វប្បធម៌ សាសនា ប្រពៃណីទំនៀមទម្លាប់ ពីសំណាក់យួនគ្រប់កាលសម័យ មិនថាជាប្រទេសនេះកាន់លិទ្ធិសេរី ឬកុម្មុយនីស្តឡើយ។ ភាពជាក់ស្តែងដែលជាលទ្ធផលនៃនយោបាយរបស់យួននេះ បានធ្វើឱ្យជនជាតិខ្មែរនៅលើទឹកដីនោះ បាត់បង់សិទ្ធិសេរីភាពគ្រប់បែបយ៉ាង ពីឋានៈជាម្ចាស់ដើមនៃទឹកដីរហូតដល់សភាពស្លុតរន្ធត់ថា អាចឈានដល់ការរលាយពូជសាសន៍។ ហើយរឿងនេះវាបន្តតាំងពីអតីតកាលមកដល់បច្ចុប្បន្នកាល និងបន្ត

ទៅអនាគតទៀត លុះត្រាផុតពូជខ្មែរនៅកម្ពុជាក្រោម។ យើងជាខ្មែរក្រោមបានត្រូវអ្នកដឹកនាំឃួនរុញផ្លប់នឹងជញ្ជាំងទៅហើយ!

- តើយើងត្រូវរស់នៅយ៉ាងដូចម្តេច?

ដើម្បីរស់ មនុស្សយើងត្រូវការ៖ ខ្យល់ដកដង្ហើម ទឹក និងម្ហូបអាហារ សម្លៀកបំពាក់ កន្លែងដេក ឱសថព្យាបាល។ ប៉ុន្តែបើបានត្រឹមតែមានអាយុវែង ដោយមិនបានធ្វើអ្វីជាប្រយោជន៍សាធារណៈ ប្រយោជន៍សង្គមជាតិ ជីវិតនោះក៏សឹងតែគ្មានន័យដែរ។ លោក **រ៉ាល់ វ៉ាល់ដូអេម៉ឺសុន** បានពោលថា មិនមែនជាប្រវែងរបស់ជីវិតទេ គឺជម្រៅរបស់ជីវិត។ It is not length of life, but depth of life. Ralph Waldo Emerson តើសុភមង្គលអាចកើតមានចំពោះខ្លួនយើងយ៉ាងណា នៅពេលដែលឪពុក ម្តាយ ញាតិសណ្តាន មាមីង បងប្អូនរាប់លានអ្នកនៅកម្ពុជាក្រោម រស់នៅក្នុងស្ថានភាពងងឹតស្លប់គ្មានសង្ឃឹមនោះ ? សកម្មជនសិទ្ធិមនុស្សនៃប្រទេសភូមា អ្នកស្រី **អុងសានស៊ូជី** បានរំលឹកមនុស្សយ៉ាងដូច្នេះ៖ Burmese human rights icon Aung San Suu Kyi said: “Don’t just sit there. Do something.” «កុំគ្រាន់តែអង្គុយនៅទីនោះ ត្រូវធ្វើអ្វីមួយ» ចំណែកលោក **ម៉ាទីន លូថឺ គីង** អ្នកដឹកនាំទាមទារសេរីភាព របស់ជនជាតិស្បែកខ្មៅ បានពោលដូច្នេះ៖ «យើងត្រូវតែតម្រង់ខ្នងឱ្យត្រង់ ធ្វើការដើម្បីសេរីភាពរបស់យើង។ មនុស្សម្នាក់មិនអាចជិះពីលើខ្នងយើងបានទេ លុះត្រាតែយើង ឱនឱ្យគេជិះ»។ American civil rights leader Martin Luther King, Jr., told African-Americans: “We must straighten our backs and work for our freedom. A man can’t ride you unless your back is bent.” ហើយនេះជាពុទ្ធវចនៈរបស់ព្រះបរមគ្រូ ៖ «ស្រោចស្រង់ខ្លួនដោយខ្លួនឯង កុំរំពឹងចាំគេដទៃ គ្មានអ្នកណាជួយយើងក្រៅពីខ្លួនយើងទេ»។ Buddha counseled. “Work out your own salvation, No one saves us but ourselves. ”

- តើយើងសង្ឃឹមលើអ្វីនៅថ្ងៃស្អែក?

ថ្ងៃស្អែក គឺថ្ងៃនេះ។ Tomorrow is Today អ្វីដែលអ្នកធ្វើនៅថ្ងៃនេះ គឺជាសេចក្តីសង្ឃឹមសម្រាប់ថ្ងៃស្អែក។ ដាំដើមឈើ អាចត្រូវការពេលវេលាដប់ឆ្នាំ។ ដាំមនុស្សអាចត្រូវការពេលពីរ ឬបីជង់ ឬច្រើនជង់ លើសពីដាំដើមឈើ។ ដោយយើង គឺខ្មែរក្រោមជាអ្នកត្រូវធ្វើការដើម្បីសង្គ្រោះខ្លួនឯង ខ្មែរក្រោមទាំងអស់គ្នាត្រូវរំដោះខ្លួនពីភាពអវិជ្ជា ភាពភ័យខ្លាច បាក់ស្បាត ភាពសម្ងំយកសុខ លះបង់គំនិតប្រកាន់បក្សពួក មានសេចក្តីក្លាហានចូលរួមការងារសង្គមជាតិ ហើយត្រូវចូលរួមក្នុងសកម្មភាពបង្កើនធនធានមនុស្ស ឱ្យទទួលការសិក្សាអប់រំសម្រាប់អនាគត ព្រោះថ្ងៃស្អែក គឺជាលទ្ធផលរបស់ថ្ងៃនេះ ម៉ោងនេះ នាទីនេះ។ យើងទាំងអស់គ្នា ត្រូវដាំសេចក្តីសង្ឃឹមនៅពេលនេះ។ ព្រោះស្អែកគឺថ្ងៃនេះ។ ដោយ៖ សឹង សម្រេច/VOKK

តពីទំព័រ ១ របស់ផងយើងនៅថ្ងៃខាងមុខ ដើម្បីឈានទៅដល់ សម្រេចវាសនាខ្លួនឯង ក្នុងពេលខាងមុខនេះបាទ! កម្មវិធីថ្ងៃនេះយើងមានភាពសប្បាយយ៉ាងខ្លាំង ដោយសារមានការចូលរួមពីសំណាក់បងប្អូនខ្មែរកម្ពុជាកណ្ដាល ជាច្រើនបាទ! ក្នុងនោះមានការចូលរួមពី សមាគមរបស់ខ្មែរកម្ពុជាកណ្ដាល និងបងប្អូនខ្មែរកម្ពុជាកណ្ដាលមួយចំនួនទៀត ក្នុងនោះមានពួកខាងបណ្ឌិត ខាងនិស្សិត និងខាងសាស្ត្រាចារ្យ ទៀតបាទ! មានទាំងព្រះសង្ឃ ទាំងចាស់ទុំ និងយុវជនទៀតបាទ! ការចូលរួមក្នុងថ្ងៃនេះ មានប្រហែលជាង១០០ នាក់បាទ! មានលោកប្រធានសហព័ន្ធខ្មែរកម្ពុជាក្រោម គឺលោក **ថាច់ ង៉ុក ថាច់** គាត់បានចូលរួមជាអធិបតីផងដែរបាទ! ហើយជាមោទនភាពសម្រាប់ សហព័ន្ធខ្មែរកម្ពុជាក្រោមប្រចាំនៅទីក្រុង Toulouse នេះបានអញ្ជើញសាខាសហព័ន្ធខ្មែរកម្ពុជាក្រោម ពីប្រទេសផ្សេងៗដូចជា នៅប្រទេសស្វីស ហើយនិងនៅខេត្ត Lyon ហើយនៅសាខាមួយចំនួនផ្សេងៗទៀតបាទ! បានមកចូលរួមយ៉ាងគគ្រឹកគគ្រេងដែរបាទ! កម្មវិធីនេះ ទី១ គឺ យើងធ្វើតាមរបៀបព្រះពុទ្ធសាសនា គឺមានការរាប់បាត្រ ប្រគេនចង្ហាន់ដល់ព្រះសង្ឃ ទី២ទៀត គឺខ្ញុំផ្ទាល់ជាប្រធានសហព័ន្ធខ្មែរកម្ពុជាក្រោមប្រចាំខេត្ត Toulouse បានអាននូវសុន្ទរកថារបស់លោកអធិបតី **តោ គឹមថុង** នោះដែរបាទ! បន្ទាប់មកទៀត មានការសម្ដែងសុន្ទរកថារបស់ អនុប្រធានសហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំខេត្ត Toulouse ហើយនិងការសម្ដែងសុន្ទរកថា របស់លោកប្រធាសហព័ន្ធខ្មែរកម្ពុជាក្រោម គឺលោក **ថាច់ ង៉ុកថាច់** បាទ! ខ្ញុំសង្កេតឃើញថា កម្មវិធីនៅថ្ងៃនេះមានភាពឱឡារិកយ៉ាងសម្បើមណាស់ បងប្អូនខ្មែរយើងទាំងអស់ដែលមកចូលរួម គឺមានការចាប់អារម្មណ៍យ៉ាងច្រើន ទៅលើចរន្តនយោបាយរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ជាពិសេសអំពីភាពសាមគ្គីភាពរវាងខ្មែរ និងខ្មែរ ហ្នឹងគេបានចាប់អារម្មណ៍យ៉ាងច្រើន និងគោលនយោបាយរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមនេះបាទ! ខ្ញុំមានសង្ឃឹមយ៉ាងច្រើនថាឆ្នាំដល់ ខ្ញុំនឹងរៀបចំបុណ្យទិវាបាត់ទឹកដីខ្មែរកម្ពុជាក្រោមនេះ សង្ឃឹមថានឹងមានបងប្អូនខ្មែរកណ្ដាលនេះ នឹងមកចូលរួមច្រើនជាងនេះទៅទៀតបាទ! ខ្ញុំសូមផ្ដាំ និងផ្ញើជូនបងប្អូនជនរួមជាតិយើង ដែលនៅក្នុងស្រុកហ្នឹង គឺថា ថ្ងៃនេះគឺជាថ្ងៃសម្រាកជុំមួយរបស់បងប្អូនខ្មែរកម្ពុជាក្រោមយើងទាំងអស់បាទ! មកពីយើងបានអញ្ជើញ បានឃើញនូវវត្តមានរបស់បងប្អូនខ្មែរទាំងអស់មកចូលរួមនេះ គឺជាជ័យជំនះមួយ យ៉ាងសម្បើមណាស់បាទ! បង្ហាញនូវ លក្ខណៈសាមគ្គីភាពជាវិជ្ជមានបាទ! ដូច្នេះយើងឃើញថា នេះជាគោលដៅរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមយើង ដែលឈានទៅរកការរំដោះទឹកដីរបស់យើង និងឈានទៅរកសិទ្ធិសេរីភាពជូនបងប្អូននៅក្នុងស្រុកដែរ ដូច្នេះសូមឲ្យបងប្អូនកុំឲ្យអស់សង្ឃឹម គឺគ្រប់វិនាទី



ទិដ្ឋភាពទឹកដីកម្ពុជាក្រោម

គ្រប់កាលៈទេសៈ គឺថាបងប្អូននៅខាងក្រៅមិនដែលបំភ្លេច មិនដែលលះបង់បងប្អូនដែលនៅក្នុងស្រុកនោះទេបាទ! សូមផ្តាំផ្ញើប៉ុណ្ណឹងបាទ! សូមកុំឲ្យអស់សង្ឃឹមឲ្យសោះបាទ! ”។ លោក **ថាច់ ង៉ុកថាច់** ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម ដែលជាអធិបតីនៅក្នុងកម្មវិធីនេះ បានថ្លែង រៀបរាប់អំពីគោលការណ៍របស់សហព័ន្ធយ៉ាងដូច្នេះ “សហព័ន្ធខ្មែរកម្ពុជាក្រោម ទោះបីតស៊ូនៅលើទឹកដីកម្ពុជាក្រោមក៏ដោយ តស៊ូនៅខាងក្រៅក៏ដោយ ក៏ពួកខ្ញុំហ្នឹងជាខ្មែរដែរ ពិសេស យើងមានភារកិច្ចដាស់តឿនខ្មែរយើងទាំងអស់គ្នា ព្រោះខ្ញុំចង់មានជំនឿថា សហព័ន្ធខ្មែរកម្ពុជាក្រោម ដែលធ្វើសព្វថ្ងៃហ្នឹងមិនមែនធ្វើដើម្បីបង្កើតក្រុមគណបក្សទេ គឺធ្វើដើម្បីការពារប្រទេសជាតិ ដើម្បីការពារខ្មែរ ដើម្បីការពារបូរណភាពទឹកដីយើង ទាំងទឹកដីបច្ចុប្បន្ន ទាំងទឹកដីដែលបាត់បង់ទៅហើយ អញ្ចឹងមិនថាបាត់បង់១០០-២០០ឆ្នាំនោះទេ អ្វីក៏ដោយបាត់បង់ក៏នៅជាទ្រព្យសម្បត្តិរបស់យើង ត្រឡប់មកវិញ កាលពីឆ្នាំទៅវិញ ខែ១០ ខ្ញុំបានមកទីហ្នឹងជួបអស់លោកចំនួនច្រើននៅទីនេះ ក៏ប៉ុន្តែក្នុងរយៈពេលខ្លីហ្នឹង សហព័ន្ធខ្មែរកម្ពុជាក្រោមបានធ្វើស្អីខ្លះ ដោយយើងឈរធ្វើនៅលើផែនការរបស់សហព័ន្ធបីហ្នឹងគឺ **កិច្ចការនៅលើអន្តរជាតិ កិច្ចការនៅប្រទេសកម្ពុជា** ហើយនិង**នៅកម្ពុជាក្រោម**។ គោលការណ៍ គឺកិច្ចការរបស់សហព័ន្ធហ្នឹង គឺយើងធ្វើកិច្ចការបីនោះ គឺទី១ យើងធ្វើការជាមួយក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលនៅទីក្រុងហ្សឺណែវហ្នឹង ដោយយើងពិនិត្យមើលថាតើសន្ធិសញ្ញាសិទ្ធិមនុស្ស កតិកាសញ្ញាសិទ្ធិមនុស្ស ដែលរដ្ឋាភិបាលកុម្មុយនីស្តយួន គេចុះហត្ថលេខាសន្ធិសញ្ញាណាខ្លះ យើងតវ៉ារឿងហ្នឹងដូចជា គេចុះសន្ធិសញ្ញារឿងគោរពនូវជំនឿសាសនា យើងជំរុញរឿងទាំងអស់ហ្នឹងប្រាប់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ឲ្យគេទៅកម្ពុជាក្រោម គេធ្វើដំណើរទៅមួយសារពីសារថា ហើយនៅកម្ពុជាក្រោមហ្នឹង ជាអ្នកកាន់ព្រះពុទ្ធសាសនាត្រូវយួនហ្នឹងរំលោភ ហើយព្រះពុទ្ធសាសនាដែលខ្មែរចងចាំ ដែលខ្មែរមានជំនឿ តែខ្មែរមិនមានសិទ្ធិសម្រេចគ្រប់គ្រងលើវាសនា ជំនឿរបស់ខ្លួនឯង ព្រះពុទ្ធសាសនាត្រូវឋិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល កុម្មុយនីស្តយួននេះគឺត្រូវគេរំលោភហើយ តែផ្ទុយទៅវិញ ព្រះសង្ឃខ្មែរក្រោមនៅក្នុងស្រុកមួយចំនួន អស់លោកមួយចំនួន ដែលគាត់មើលឃើញថា រដ្ឋាភិបាលយួនឥឡូវហ្នឹងគេបន្ធូរបន្ថយ វត្តខ្លះនៅ

*កម្ពុជាក្រោមហ្នឹង វត្តខ្លះដូចវាំងស្តេចចិន បើបងប្អូនណាបានទៅកម្ពុជាក្រោម យើងពិតជាមើលឃើញចឹង មើលឃើញជាហូរហែរ ព្រះសង្ឃក៏ធ្វើបុណ្យបាន បងប្អូនក៏ធ្វើទានផ្សេងៗហ្នឹងបាន បើយើងមើលទៅឃើញថា មានសិទ្ធិសេរីភាព ប៉ុណ្ណឹង គ្រប់គ្រាន់ ខ្លះថាបងប្អូនខ្មែរកម្ពុជាក្រោម មិនបាច់តវ៉ាអីទៀតទេ គេប្រគល់សេរីភាពយើងប៉ុណ្ណឹងឃើញថាគួរសមហើយ ក៏ប៉ុន្តែ យើងមើលទៅវិញ បើសិនជាគេឲ្យសេរីភាពយើងទៅវិញ គេអត់គ្រប់គ្រងយើងទេ ព្រះពុទ្ធសាសនាហ្នឹងនៅក្រោមការគ្រប់គ្រងរបស់យួនហ្នឹងគឺយើងតវ៉ាទៅតាមហ្នឹង"។ អ្នកស្រី ថាច់ សុភាព ដែលជាប្រធានសាខាសហព័ន្ធខ្មែរកម្ពុជាក្រោមប្រចាំប្រទេស ស្វីស បានចូលរួមក្នុងកម្មវិធីនេះ បានរៀបរាប់អំពីទុក្ខវេទនារបស់បងប្អូនខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅឯមាតុភូមិកម្ពុជាក្រោមសព្វថ្ងៃ ដោយខ្សឹកខ្សួល អួលដើមកថា "ជួបព្រះអង្គ* ***គឹម មឿន*** *ព្រះអង្គ* ***ទឹម សាខន*** *ព្រះអង្គ* ***យ៉ញ តូន*** *ដែលជាប់គុករបស់យួន មួយអង្គៗពីរ-បីឆ្នាំ ហើយពេលនេះខ្ញុំមានរឿងមួយដែលគួរអស្ចារ្យ ចំពោះបងប្អូនខ្មែរយើងត្រូវយួនកាប់ក្បាលឈ្មោះ* ***ចៅ ណៃត*** *នៅក្នុងឆ្នាំទៅមុិញ ភ្ជុំបិណ្ឌ ខ្ញុំមិននឹក មិនស្មានថាបងប្អូនខ្មែរកម្ពុជាក្រោមយើង ដែលនៅទឹកដីកម្ពុជាក្រោម ត្រូវយួនធ្វើបាបមកដល់សព្វថ្ងៃនេះ។ ហើយខ្ញុំមានមោទនភាពជាទីបំផុតដែលយើងមានលោកប្រធានប្រតិបត្តិ សហព័ន្ធខ្មែរកម្ពុជាក្រោមបានផ្សព្វផ្សាយរឿងបងប្អូនខ្មែរកម្ពុជាក្រោមយើង ក្នុងនាមខ្ញុំជាខ្មែរក្រោមមួយរូប ដែលលោកឪពុកនៅកម្ពុជាក្រោម ឆ្នាំ១៩៤៥ កាលជំនាន់បារាំង ដែលបានរត់មកកម្ពុជាកណ្តាលនេះ ហើយដែលឥឡូវត្រូវគេសម្លាប់ហើយទាំងពូជ។ ដល់សតវត្សរ៍ទី២១នេះទៀត រហូតមកដល់សព្វថ្ងៃនៅតែយួនគាបសង្កត់ បងប្អូនខ្មែរយើងរហូតដល់ កាប់សម្លាប់* ***ចៅ ណៃត*** *ដូច្នេះខ្ញុំទទួលយកអត់បាន។ ដូចដែលបងប្អូនយើងបានឃើញហើយ ខ្ញុំមិនជម្រាបទេ មានខ្លះបងប្អូនខ្មែរយើងគាត់ចុះទៅខ្មែរ គាត់ឃើញច្បាស់ ដែលនៅបឹងកក់ ពេលដែលខ្ញុំមកពីធ្វើការ ខ្ញុំបើកទូរទស្សន៍ ខ្ញុំឃើញកូនពរក្មេងស្រីមួយអាយុប្រាំឆ្នាំ ដែលគេដេញគាត់ចេញពីផ្ទះ គាត់ថា "ដេញខ្ញុំចេញពីផ្ទះ តើឲ្យខ្ញុំទៅនៅឯណា?" សំដីហ្នឹង នៅជាប់ខួរក្បាលខ្ញុំរហូតដល់សព្វថ្ងៃ នេះ ខ្ញុំទទួលយកអត់បាន ហេតុដូច្នេះខ្ញុំនឹកឃើញថា បើបងប្អូនយើងនៅដីកម្ពុជាកណ្តាលត្រូវគេធ្វើបាប តើយើងអ្នកនៅខាងក្រៅ គេងលក់ស្កប់ស្កល់ឬ? ខ្ញុំទទួលយកអត់បាន។ ដូច្នេះខ្ញុំសង្ឃឹមថា ចិត្តបងប្អូនទាំងអស់គ្នា ក៏ដូចជាចិត្តខ្ញុំ ពូជកំណើតរបស់យើងមានទុក្ខ តើយើងធ្វើស្អីដើម្បីជាតិ មាតុភូមិយើង? យើងត្រូវរួបរួមគ្នា ត្រូវសាមគ្គីគ្នា ចងបាច់ មិនប្រកាន់ទេថា ខ្មែរក្រោម ខ្មែរកណ្តាល ឬខ្មែរលើ។ បើបងប្អូនទាំងអស់មានគំនិតដូចខ្ញុំចឹងខ្ញុំជឿថា ទឹកដីកម្ពុជាក្រោមមិនយូរទេ យើងនឹងបានត្រឡប់មក*

វិញដោយសារតែកម្លាំងបងប្អូនយើង នៅទីនេះ។ ពេលបើកវិទ្យុខ្មែរកម្ពុជាក្រោម ខ្ញុំឮគេនិយាយទីនេះវិទ្យុខ្មែរកម្ពុជាក្រោម ជាមាតុភូមិដ៏សែនស្រណោះរបស់យើង ខ្ញុំឮពាក្យហ្នឹង ខ្ញុំស្រក់ទឹកភ្នែកភ្លាម គ្រប់ពេលខ្ញុំអង្គុយមុខ You-Tube ខ្ញុំ យំហើយ។ ហើយគ្រួសារខ្ញុំគាត់ចេះតែថា មេចក៏ចេះតែទឹកយំអញ្ចឹង? ខ្ញុំថា យើងនៅប្រទេសគេ យើងរស់សុខស្រួលហើយ យើងញ៉ាំឆ្ងាញ់ យើងដេកស្រួល ក៏ប៉ុន្តែបងប្អូនខ្ញុំនៅក្នុងប្រទេស ខ្ញុំឃើញគេយំរាល់ថ្ងៃ។ ដោយអី? គេរឹបយកដី មិនថាក្មេង មិនថាចាស់ តើយើងធ្វើស្អីដើម្បីជាតិរបស់យើង? បងប្អូនទាំងអស់ដែលស្នេហាជាតិមានវត្តមាននៅទីនេះ ប្រហែលជាចិត្តមិនខុសពីខ្ញុំទេ ដូចគ្នាគឺជួយជាតិ ជួយមាតុភូមិយើង។ យើងឃើញហើយនៅដីកម្ពុជាក្រោមយើងត្រូវយួនគាបសង្កត់។ គ្រប់ពេលដែលខ្ញុំនិយាយក្នុងវិទ្យុខ្មែរពិភពលោក វិទ្យុកម្ពុជាក្រោម ខ្ញុំថា ខ្ញុំមិនចង់ឲ្យទឹកដីសព្វថ្ងៃក្លាយជាកម្ពុជាក្រោមទី២ទៀត”។ អ្នកស្រី សុខ ជា ជាខ្មែរកណ្តាល ដែលមានដើមកំណើតបច្ចុប្បន្នរស់នៅខេត្ត Toulouse ប្រទេសបារាំង បានចូលរួម ហើយបានមានចំណាប់អារម្មណ៍យ៉ាងដូច្នេះ “មកពីស្រុកខ្មែរ ខ្ញុំរស់នៅប្រទេសបារាំង ខ្ញុំមានសេចក្តីរំភើបរីករាយ ព្រោះអីខ្ញុំជាខ្មែរដែរ ហើយខ្ញុំមានមោទនភាព ព្រោះអីខ្មែរបានរួមគ្នាដើម្បីទាមទារឯករាជ្យ ទាមទារសិទ្ធិសេរីភាព ភាពស្មើគ្នាដើម្បីឲ្យប្រជាជនខ្មែរក្រោមទាំងអស់ មានសិទ្ធិសេរីភាពឡើង កុំឲ្យយួនត្រួតត្រាយូរលង់អង្វែងតទៅទៀត មើលទៅឃើញថាពិបាកណាស់ ខ្ញុំមានសង្ឃឹមថា នឹងទទួលបានឯករាជ្យ ព្រោះអីបងប្អូនខ្មែរនៅទីនេះរួមសាមគ្គីគ្នាដើម្បីជួយបងប្អូនខ្មែរ ដែលរស់នៅឯស្រុកខ្មែរក្រោមនោះ ឲ្យមានសេរីភាពរួចពីអាណានិគមន៍”។ ទន្ទឹមនឹងនោះដែរ អ្នកស្រីបានផ្តែរផ្តាំផ្ញើទៅដល់កូនចៅខ្មែរគ្រប់រូប ឲ្យមានស្មារតីស្រឡាញ់ជាតិ មាតុភូមិរបស់ខ្លួន “ខ្ញុំមានការផ្តាំផ្ញើទៅដល់បងប្អូន ស្ត្រីខ្មែរ កូនខ្មែរទាំងអស់ទាំងប្រុសទាំងស្រីហ្នឹង ឲ្យមានការភ្ញាក់រឭកឡើង ឲ្យដឹងថាខ្មែរសព្វថ្ងៃនេះ មិនមែនតែខ្មែរកណ្តាលទេ នៅមានខ្មែរក្រោមទៀតតាមខ្ញុំដឹងថា បច្ចុប្បន្ននេះ នៅឯស្រុកខ្មែរកណ្តាលហ្នឹងកូនខ្មែរមិនដឹងថាមានដីខ្មែរក្រោមទេ ព្រោះអីខ្ញុំមកនេះយូរដែរហើយ តាំងពីឆ្នាំ២០០៥ ខ្ញុំមកនៅស្រុកបារាំង ហើយខ្ញុំក៏បានរៀនចប់ចេះដឹងមកពីនោះដែរ ។ អញ្ចឹងហើយខ្ញុំសូមផ្តាំទៅកូនខ្មែរទាំងអស់ហ្នឹងទាំងរស់នៅឯខ្មែរក្រោម និងខ្មែរកណ្តាល ខ្មែរលើហ្នឹងឲ្យដឹងថា គេចង់យកទឹកដីយើងហើយ ឲ្យយើងហ្នឹងភ្ញាក់រឭកឡើងឲ្យយើងហ្នឹងសាមគ្គីគ្នាឡើងកុំបែកបាក់គ្នាតទៅទៀត តិចទៀតហ្នឹង ទឹកដីខ្មែរនឹងបាត់បង់ លែងឃើញមានខ្មែរនៅក្នុងផែនទីពិភពលោកទៀតហើយ”។ សូមបញ្ជាក់ផងដែរថា យោងតាមឯកសារប្រវត្តិសាស្ត្របានសរសេរថា កាលថ្ងៃទី ២៨ ខែមីនា ឆ្នាំ១៩៤៩ ប្រធានាធិបតីបារាំង

ឈ្មោះ ***វ៉ាំងសង់ អូរីយ៉ូ*** បានចុះកិច្ចព្រមព្រៀងប្រគល់ទឹកដីកម្ពុជាក្រោម ឲ្យវៀតណាម ដោយវៀតណាម យល់ព្រមបង្កើតរដ្ឋាភិបាលមួយនៅក្នុងក្រុមសភាបារាំងថា រដ្ឋវៀតណាម ហើយបារាំងសង្ឃឹមថា ការប្រគល់ទឹកដីកម្ពុជាក្រោមឲ្យស្តេច**បាវដាយ** ដោយគេអាចរក្សានូវឥទ្ធិពលរបស់ខ្លួនបានយូរអង្វែង នៅទឹកដីកូសាំងស៊ីន ព្រមទាំងទម់ស្កាត់របបកុម្មុនីស្ត ហូជីមិញ។ លុះដល់ថ្ងៃ០៤ មិថុនា ឆ្នាំ១៩៤៩ ដដែល ប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូ បានប្រកាសជាផ្លូវការ ប្រគល់ទឹកដីកម្ពុជាក្រោមឲ្យវៀតណាមជាផ្លូវការ ដោយមានផ្ទៃដីចំនួន ៦៨០០០ គីឡូម៉ែត្រក្រឡា មាន៦ខេត្ត/ក្រុង កាលណោះ។ បច្ចុប្បន្នបំបែកទៅជា ២១ខេត្ត គិតមកដល់ពេលនេះ ការបាត់បង់ទឹកដីកម្ពុជាក្រោម មានរយៈពេល៦២ឆ្នាំមកហើយ៕

# សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ បើកសិក្ខាសាលាស្តីពីច្បាប់ដល់ក្រុមការងារ




ក្រុមសិក្ខាកាម និងគ្រូបណ្តុះបណ្តាលច្បាប់ នៃសមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍

សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ ហៅកាត់ថា KKKHRDA ដែលមានទីស្នាក់ការ ឋិតនៅក្នុងសហគមន៍បុរីព្រៃនគរ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ បានបើកសិក្ខាសាលាមួយមានរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី ២៩ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ដោយសិក្សាទៅលើ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ភូមិបាល និងច្បាប់សញ្ញាតិ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការជំនួយឧបត្ថម្ភពីអង្គការ Diakona នៅកម្ពុជា និងមានលោក **ថ្រី ហ៊ង** ទីប្រឹក្សាផ្នែកច្បាប់ នៃអង្គការ Diakonia និងអង្គការ Forumsyd Cambodia ជាគ្រូបណ្តុះបណ្តាល។

វគ្គសិក្ខាសាលានេះ មានការចូលរួមពីក្រុមការងាររបស់ KKKHRDA ចំនួន២៣រូប នៃបណ្តាញសហគមន៍ចំនួន៦គឺ ខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តក្រចេះ ខេត្តបាត់ដំបង និងទីក្រុងភ្នំពេញ។ ក្រៅពីនោះក៏មានការចូលរួមពីគណៈកម្មការស្នូលនៃបណ្តាញយុវជនខ្មែរកម្ពុជាក្រោមមួយចំនួនផងដែរ។

លោក សឺន ជុំជួន មន្ត្រីសម្របសម្រួលនៃសមាគម KKKHRDA បានមានប្រសាសន៍ថា ដោយសារការយល់ដឹងផ្នែកច្បាប់ នៃក្រុមការងាររបស់លោកនៅមានកម្រិតទាប ដូច្នេះ

ការបើកវគ្គបណ្តុះដណ្តាលនេះ គឺដើម្បីពង្រឹងសមត្ថភាពដល់ពួកគេបន្ថែមទៀត សម្រាប់ជួយប្រជាពលរដ្ឋ នៅក្នុងបណ្តាសហគមន៍នីមួយៗ "ចឹងយើងជឿជាក់ថាថ្ងៃក្រោយ ទាំងបុគ្គលិករបស់សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ ទាំងបុគ្គលិកដែលបម្រើការនៅក្នុងកម្មវិធី បណ្តាញយុវជនខ្មែរកម្ពុជាក្រោមហ្នឹង នៅពេលដែលចុះធ្វើការជាមួយពួកគាត់ហ្នឹង យើងអាចនឹងចែករំលែកបទពិសោធន៍ហ្នឹងទៅដល់ពួកគាត់ ហើយជួយចូលរួមសម្របសម្រួល នៅពេលដែលមានបញ្ហាដែលមានទំនាស់កើតឡើងនៅក្នុងសហគមន៍"។

លោក នួន រី មកពីខេត្តបាត់ដំបងបានមានប្រសាសន៍ថា លោកបានធ្វើការជាមួយ KKKHRDA មានរយៈពេលជាងដប់ឆ្នាំមកហើយ ហើយលោកបានជួបប្រទះបញ្ហារបស់ខ្មែរកម្ពុជាក្រោមជាច្រើនដូចជា បញ្ហាអត្តសញ្ញាណប័ណ្ណ បញ្ហាដីធ្លី អំពើហិង្សាក្នុងគ្រួសារ ជាដើម។

រីឯលោក ឌី វណ្ណថន មកពីខេត្តកណ្តាល បានលើកឡើងពីបញ្ហា អត្តសញ្ញាណប័ណ្ណ ដែលអាជ្ញាធរមូលដ្ឋាន មិនព្រមអនុញ្ញាតឲ្យខ្មែរកម្ពុជាក្រោម ប្រើប្រាស់ទីលំនៅនៅស្រុកកំណើតរបស់ខ្លួន នៅកម្ពុជាក្រោមនោះទេ។ លោកក៏បានមានប្រសាសន៍ថា ការចូលរួមសិក្ខាសាលានេះ ដើម្បីជួយប្រជាពលរដ្ឋក្នុងពេលមានបញ្ហា។

លោក ភួង សុខា មកពីខេត្តស្វាយរៀងបានឲ្យដឹងថា ទាំងអាជ្ញាធរ ទាំងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមមួយចំនួននៅទីនោះ មិនទាន់យល់ដឹងច្បាស់ អំពីគោលបំណងរបស់សមាគម KKKHRDA នៅឡើយទេ។

ចំណែកឯលោក ចន្ទ សុខ ជាសមាជិកក្រុមប្រឹក្សាឃុំឱ្យម ស្រុកស្អួល ខេត្តក្រចេះ បានឲ្យដឹងផងដែរថា ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមនៅខេត្តក្រចេះរស់នៅដាច់ឆ្ងាយពីគ្នា លំបាកក្នុងការទំនាក់ទំនងគ្នា និងជួយគ្នាទៅវិញទៅមក "យើងយកទៅផ្សព្វផ្សាយ ចែកជូនដល់បងប្អូនប្រជាពលរដ្ឋយើង ជាពិសេសបងប្អូនខ្មែរកម្ពុជាក្រោម ដែលគាត់មិនយល់ច្បាប់អំពីច្បាប់ព្រហ្មទណ្ឌ ច្បាប់ភូមិបាល និងសញ្ជាតិហ្នឹង។ ហើយទី២ ដើម្បីការពារគាត់ដែលងាយរងគ្រោះ ដែលគាត់មិនសូវបានចេះច្បាប់ហ្នឹង ដែលអាជ្ញាធរដែនដី សមត្ថកិច្ចរំលោភមកលើគាត់"។

រីឯលោក យឹម យ៉ាត មកពីខេត្តកំពង់ស្ពឺ បានមានប្រសាសន៍ឲ្យដឹងថា បញ្ហាជាចំបងរបស់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមនៅទីនោះគឺគ្មានដីស្រែចំការ សម្រាប់ប្រកបមុខរបររកស៊ីឡើយ ហើយការមកចូលរួមវគ្គសិក្ខាសាលានេះ ដើម្បីយកចំណេះដឹង ជួយប្រជាពលរដ្ឋក្រីក្រក្នុងការស្វែងរកដីធ្លីប្រប្រាស់ស្របច្បាប់។

ដោយឡែកកញ្ញា ផន ឈុនលី ជំនួយការកម្មវិធី នៃសមាគម KKKHRDA និងជាគណៈកម្មការស្អួល នៃបណ្តាញយុវជនខ្មែរកម្ពុជាក្រោម ដែលបានចុះជួបប្រជាពលរដ្ឋខ្មែរកម្ពុជា

តទៅទំព័រ៣២

# មេធាវីជនជាតិសិង្ហបុរី ស៊ើបអង្កេតនៅលើសំណុំរឿងក្តី ឧក្រិដ្ឋកម្មមកលើខ្មែរក្រោម




ទិដ្ឋភាពអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

យោងតាមកាសែត The Straits Times របស់សិង្ហបុរី បាននិយាយឲ្យដឹងថា មេធាវីជនជាតិសិង្ហបុរី នឹងថ្កោលទោសមេដឹកនាំខ្មែរក្រហម។ សាលាច្បាប់ SMU ប្រចាំសិង្ហបុរី នឹងតំណាងឲ្យជនរងគ្រោះនៅក្នុងរបបវាលពិឃាត។ ការកាត់ក្តីមេដឹកនាំខ្មែរក្រហមចំនួន៤នាក់ ដែលបានអូសពេលវេលាយ៉ាងយូរ បានចាប់ផ្តើមឡើងនៅថ្ងៃច័ន្ទកន្លងទៅនេះ។ មេធាវីជនជាតិសិង្ហបុរីលោក Mahdev Mohan ជាមេធាវីម្នាក់ក្នុងចំណោមមេធាវីតំណាងឲ្យជនរងគ្រោះ នៅក្នុងរបបខ្មែរក្រហម។ លោក Mahdev Mohan អាយុ៣២ឆ្នាំ ជាគ្រូបង្រៀនផ្នែកច្បាប់ នៅសាកលវិទ្យាល័យសិង្ហបុរី បានដឹកនាំក្រុមរបស់លោក ដើម្បីស៊ើបអង្កេតទៅលើរឿងក្តីឧក្រិដ្ឋកម្ម ទៅលើខ្មែរក្រោម និងជនជាតិដើមភាគតិចដទៃទៀតក្នុងរបបខ្មែរក្រហម ចាប់តាំងពីឆ្នាំ ១៩៧៥-១៩៧៩ ដែលបានសម្លាប់មនុស្សអស់រាប់លាននាក់។ ភស្តុតាង ដែលបានផ្តល់ទៅតុលាការនៅក្នុងលើកទីមួយ ខែកក្កដាកន្លងទៅ មិនបាននិយាយអំពីបញ្ហាកាប់សម្លាប់ខ្មែរក្រោមឡើយ។ លើកនេះ Mohan និងលោកមេធាវី Delphia Lim ដែលជាជនជាតិសិង្ហបុរី ព្រមទាំងមេធាវី៤នាក់ផ្សេងទៀត ជនជាតិខ្មែរ និងជនជាតិអង់គ្លេស បានសហការគ្នាប្រមែប្រមូលឯកឯសារភស្តុតាង ដែលទាក់ទិននឹងឧក្រិដ្ឋកម្មលើខ្មែរក្រោមដើម្បីបញ្ជូនទៅតុលាការ។ ជនជាតិខ្មែរក្រោម គឺជាជនជាតិដើម រស់នៅលើទឹកដីវៀតណាមភាគខាងត្បូងសព្វថ្ងៃ ហើយត្រូវបានពួកយួនលាបពណ៌ក្លាយទៅជាយួន។ ហេតុដូច្នេះហើយធ្វើឲ្យរបបខ្មែរក្រហម ចោទថាជាយួន ហើយក៏បានធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរព្រៃផ្សៃមកលើខ្មែរក្រោម ដោយកាប់សម្លាប់ និងចាប់ដាក់គុកជាដើម នេះបើយោងតាមសម្តីរបស់លោក Mohan ។ ក្រុមរបស់លោក Mohan ក៏បានបង្ហាញ នូវជនរងគ្រោះខ្មែរក្រោម ចំនួន ៨៣នាក់ ដើម្បីធ្វើជាភស្តុតាងនៅក្នុងការបង្កើតសំណុំរឿងពិសេសថ្មីមួយទៀត ដែលផ្តោតតទៅលើបញ្ហាខ្មែរក្រោម។ ហើយសំណុំរឿងនេះពាក់ព័ន្ធ នឹងមេដឹកនាំខ្មែរក្រហម នៅតាមតំបន់នានា៕

ប្រភព ៖ VOKK

# អាជ្ញាធរយួនបំបិទសិទ្ធិសេរីភាពខ្មែរកម្ពុជាក្រោមមិនឲ្យទទួលព័ត៌មានតាមរយៈទូរទស្សន៍ខ្មែរពីកម្ពុជា



អាជ្ញាធរយួននៅតែរឹតបន្តឹងប្រជាពលរដ្ឋខ្មែរក្រោមទូទាំងដែនដីកម្ពុជាក្រោម ឲ្យដាក់ចុះនូវប្រព័ន្ធថាសផ្កាយរណប(DTV) ដែលអាចចាប់មើលឃើញនូវរាល់កម្មវិធី ផ្សាយទូរទស្សន៍ចេញពីព្រះរាជាណាចក្រកម្ពុជា។ ការដែលអាជ្ញាធរយួនបញ្ជាឲ្យដាក់ចុះ ព្រមទាំងគំរាមនឹងពិន័យទឹកប្រាក់ពី៣០លានដុងទៅនោះ បានញ៉ាំងឲ្យពលរដ្ឋខ្មែរក្រោម ទាំងព្រះសង្ឃ និងគ្រហស្ថកើតទុក្ខមិនសុខចិត្ត ដោយយល់ឃើញថា នេះជាអំពើរំលោភសិទ្ធិមួយយ៉ាងធ្ងន់ធ្ងរ ដែលអាជ្ញាធរយួនព្យាយាមកាត់ផ្ដាច់ មិនឲ្យពលរដ្ឋខ្មែរក្រោម បានឃើញ បានយល់ អំពីនាទីវប្បធម៌ អក្សរសាស្ត្រ និងព័ត៌មានសំខាន់ៗ ដែលផ្សាយចូលមកពីព្រះរាជាណាចក្រកម្ពុជា។

លោក **ថៅ ជាតិសុខា** ប្រជាពលរដ្ឋខ្មែរក្រោមមួយរូបនៅខេត្តមាត់ជ្រូក បានឲ្យដឹងតាមរយៈវិទ្យុសម្លេងកម្ពុជាក្រោម ពីទឹកដីកម្ពុជាក្រោមថា បច្ចុប្បន្ននេះអាជ្ញាធរយួនបានបង្គាប់ឲ្យប្រជាពលរដ្ឋខ្មែរនៅកម្ពុជាក្រោម ដាក់ចុះនូវឧបករណ៍ថាសផ្កាយរណប (DTV) ឬផ្អាកការមើលកម្មវិធីទូរទស្សន៍ជាភាសាខ្មែរ ដែលផ្សាយចេញពីព្រះរាជាណាចក្រកម្ពុជា។ លោក សុខា បានមានប្រសាសន៍ឲ្យដឹងបន្ថែមថា អាជ្ញាធរយួន បានដាក់កំហិតឲ្យខ្មែរក្រោមនៅខេត្តមាត់ជ្រូក ចំពោះរាល់គ្រួសារណាដែលមានប្រប្រាស់ថាសផ្កាយរណបនោះគឺត្រូវតែដាក់ចុះ ឈប់ប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ នេះ។ លោកបានឲ្យដឹងទៀតថា បើខ្មែរកម្ពុជាក្រោមណា ដែលរឹងទទឹងនៅតែមិនព្រមដាក់ថាសផ្កាយរណបនោះចុះទេ នឹងត្រូវបានអាជ្ញាធរយួនពិន័យជាទឹកប្រាក់ចំនួន៩លាន ទៅ១០លានដុង។ លោកថា បច្ចុប្បន្ននេះមានប្រជាពលរដ្ឋខ្មែរក្រោមមួយចំនួន ដោយមានការភ័យខ្លាចក៏បានដាក់ថាសផ្កាយរណបនោះចុះហើយ និងមិនហ៊ានមើលកម្មវិធីទូរទស្សន៍ ដែលផ្សាយចេញពីកម្ពុជាទៀតហើយ។ លោក សុខា បានបន្ថែមទៀតថា បើខ្មែរក្រោមណានៅតែមិនព្រមអនុវត្តតាមបញ្ជារបស់គេ នោះគេនឹងមកដាក់ចុះដោយខ្លួនឯង និងរឹបអូសយកឧបករណ៍ទាំងនោះតែម្តង។ លោកក៏បានឲ្យដឹងផងដែរថា ការហាមប្រាមនេះ គឺគេហាមតែខ្មែរក្រោមទេ ចំពោះជនជាតិយួនវិញ អាជ្ញាធរយួនមិនបានហាមមិនឲ្យប្រើប្រាស់ថាស (DTV) នោះទេ។

បុរសខ្មែរក្រោមម្នាក់ទៀត គឺលោក ជ័យ កុសល ពីខេត្តព្រះត្រពាំង ក៏បានឲ្យដឹងដែរថា នៅខេត្តព្រះត្រពាំង អាជ្ញាធរយួន ក៏បានបញ្ជាឲ្យប្រជាពលរដ្ឋខ្មែរក្រោម ដាក់ចុះនូវថាសផ្កាយរណបដែលអាចបើកមើលឃើញរាល់កម្មវិធីតាមទូរទស្សន៍ ដែលផ្សាយចេញពីទឹកដីកម្ពុជានោះដែរ។ លោក ជ័យ កុសល ក៏បានជម្រាបបន្ថែមថា អាជ្ញាធរយួនបានប្រើវិធីសាស្ត្រគំរាមផង និងលួងលោមផងដើម្បីឲ្យខ្មែរក្រោមដាក់ឧបករណ៍DTVនោះចុះ ហើយគេសន្យាថានឹងមកដាក់ជូននូវ DTV ថ្មីដល់ប្រជាពលរដ្ឋខ្មែរក្រោម។ លោក ក៏បានបញ្ជាក់ផងដែរថា ខ្មែរក្រោមមួយចំនួន បានធ្លាប់ជួបប្រទះហើយពីល្បិចនេះ គឺឧបករណ៍ថ្មីនោះ មានទ្រង់ទ្រាយតូចជាង DTV ដែលខ្មែរក្រោមកំពុងតែប្រើប្រាស់ ហើយមិនអាចបើកមើលឃើញទូរទស្សន៍ដែលចាក់ផ្សាយពីកម្ពុជាទេ។ លោក ជ័យ កុសល បានជម្រាបផងដែរថា ការហាមប្រាមរបស់អាជ្ញាធរយួននេះ គេមិនហាមក្នុងលក្ខណៈជាសាធារណទេ គឺគេហាមតាមលំដាប់លំដោយ ពីតំបន់មួយទៅតំបន់មួយ រហូតដល់ខ្មែរក្រោមព្រមដាក់ចុះនូវថាសផ្កាយរណប ហើយឈប់មើលប៉ុស្តិ៍ទូរទស្សន៍ណា ដែលអាចបើកមើលឃើញពីព្រះរាជាណាចក្រកម្ពុជា ទើបគេសុខចិត្ត។

ចំណែកឯលោក ថៅ ភក្តី ពីខេត្តឃ្លាំងក៏បានរៀបរាប់ប្រាប់ពីបញ្ហានៃការរឹតបន្តឹង និងការគាបសង្កត់សិទ្ធិ សេរីភាពខាងការទទួលព័ត៌មានពីសំណាក់អាជ្ញាធរយួន មកលើប្រជាពលរដ្ឋខ្មែរក្រោមផងដែរថា សព្វថ្ងៃនេះអាជ្ញាធរយួនមានមន្ទិលសង្ស័យថា មានព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមនៅក្នុងស្រុក មានការទាក់ទងជាមួយខ្មែរក្រោមអ្នកនៅក្រៅស្រុក សហការគ្នាដើម្បីទាមទារសិទ្ធិសេរីភាព ពីអាជ្ញាធរអាណានិគមយួន។ ប្រហែលជាដូច្នេះហើយ ទើបគេចាត់វិធានការ ត្រួតពិនិត្យរាល់សំភារៈដែលព្រះសង្ឃនៅតាមបណ្តាវត្តអារាម និងប្រជាពលរដ្ឋខ្មែរក្រោម ដែលប្រើប្រាស់កុំព្យូទ័រមានភ្ជាប់បណ្តាញ Internet វិទ្យុ និងទូរទស្សន៍ដែលភ្ជាប់ថាសផ្កាយរណប ព្រមទាំងបញ្ជាឲ្យព្រះសង្ឃខ្មែរក្រោមនៅតាមបណ្តាវត្ត និងប្រជាពលរដ្ឋខ្មែរក្រោម ឲ្យឈប់ប្រើប្រាស់សំភារៈអស់ទាំងនេះ។ លោក ថៅ ភក្តី ក៏ជម្រាបផងដែរថា មានប្រជាពលរដ្ឋខ្មែរក្រោមមួយចំនួន ដែលរឹងទទឹងមិនព្រមអនុវត្តតាមបញ្ជារបស់គេ អាជ្ញាធរយួនក៏មិនហ៊ានចាត់វិធានការយ៉ាងណា មកលើពួកគាត់ដែរទេ តែគេនៅតែកត់សំគាល់មើល និងកំណត់ចំណាំទុកថា ជាជនប្រឆាំងនឹងគេដែរ។ ស្រដៀងគ្នាទៅនឹងស្ថានភាព នៅខេត្តមាត់ជ្រូកដែរ លោក ភក្តី បានមានប្រសាសន៍ថា ទង្វើនេះអាជ្ញាធរយួន ធ្វើមកលើតែប្រជាពលរដ្ឋខ្មែរក្រោមប៉ុណ្ណោះ រីឯជនជាតិយួន គេមិនបានហាមឃាត់ ឆែកឆេរ ត្រួតពិនិត្យ ឬគំរាមកំហែងការប្រើប្រាស់ឧបករណ៍ទាំងអស់នេះទេ។

សូមជម្រាបផងដែរថា ទង្វើបែបនេះ បាន

តទៅទំព័រ១៤

# រដ្ឋអំណាចយួនបង្ខំខ្មែរក្រោម រៀនច្បាប់កុម្មុយនិស្ត



រូបថតអនុស្សាវរីយ៍ វគ្គបណ្តុះបណ្តាលការពារជាតិ សន្តិសុខ ដល់សមណសិស្សនៅវិទ្យាស្ថានព្រះពុទ្ធសាសនាខ្មែរថេរវាទ នៅទីក្រុងព្រែកឫស្សី

អាជ្ញាធរយួនខេត្តឃ្លាំង បានកោះហៅព្រះសង្ឃ និងគណៈកម្មការអាចារ្យវត្តមួយ ចំនួនទៅសិក្សាអប់រំ អំពីទ្រឹស្តីកុម្មុយនិស្តរបស់ពួកគេ ដោយពួកគេបានមកបញ្ជោត សម្លុត គំរាម កំហែង ដល់ព្រះសង្ឃ និងគណៈកម្មការអាចារ្យវត្ត កុំឲ្យជឿពាក្យសម្តីរបស់បុគ្គល អង្គការសមាគមទាំងឡាយ ដែលនៅក្រៅប្រទេស។ យ៉ាងនេះក្តី ព្រះសង្ឃ និងគណៈកម្មការអាចារ្យវត្ត បានឲ្យដឹងថា ការហាមប្រាមរបស់ពួកគេដូច្នេះ ព្រោះតែពួកគេខ្លាចអ្នកនៅខាងក្រៅស្រុក បរិហារកេរ្តិ៍ឈ្មោះ និងអំពើមិនល្អរបស់ពួកគេ ដែលប្រព្រឹត្តមកលើពលរដ្ឋខ្មែរក្រោម។

បុរសខ្មែរក្រោមម្នាក់ សូមមិនបញ្ចេញឈ្មោះបានឲ្យដឹងពីទឹកដីខេត្តព្រះត្រពាំងមកថា វគ្គបណ្តុះបណ្តាលដែលអាជ្ញាធរយួនបង្ខំឲ្យព្រះសង្ឃ និងគណៈកម្មការ អាចារ្យតាមបណ្តាវត្តទៅរៀននោះ គឺគេនិយាយអំពីការរក្សាសន្តិសុខ និងការពារប្រទេសជាតិ។ បុរសខ្មែរក្រោមរូបនេះ ក៏បានឲ្យដឹងផងដែរថា តាមអ្នកយកព័ត៌មានដឹងច្បាស់នោះគឺ មានខេត្តព្រះត្រពាំង និងខេត្តឃ្លាំង។ បានដឹង២ កន្លែងទី១ វត្តចារុំ នៅស្រុកថ្កូវ ថ្ងៃទី ១០ - ១១ - ១២ បន្ទាប់ពីនោះគឺវត្តកំពង់ជ្រៃ ស្រុកកំពង់ធំ នៅថ្ងៃ ១៣ - ១៤ - ១៥។ ចំពោះនៅខេត្តឃ្លាំង ថ្ងៃ ២១ - ២២ មិថុនា ២០១១ ដូចគ្នា។ លោកក៏បានឲ្យដឹងទៀតថា ចំពោះខេត្តព្រះត្រពាំងរៀន ២កន្លែងគឺវត្តកំពង់ជ្រៃ និងវត្តចារុំ សិក្សាអំពី ទី១ គេឲ្យយើងខិតខំសិក្សារៀនសូត្រភាសាយួន។ ទី២ គេកុំឲ្យយើងជឿអ្នកដែលនៅក្រៅប្រទេស ដែលបញ្ចុះបញ្ចូលនាំឲ្យមានការបែកបាក់សាមគ្គី។ ឯវត្តចារុំវិញ គេនិយាយអំពីរដ្ឋាភិបាលយួន មានការទាស់ទែងប្រឈមមុខនឹងសហរដ្ឋអាមេរិក គេថា ប្រសិនបើជាមានសង្គ្រាមកើតឡើង យើងទាំងអស់គ្នា ទាំងព្រះសង្ឃ ទាំងគ្រហស្ថត្រូវតែក្រោកឡើងប្រឆាំងតតាំងនឹងសហរដ្ឋអាមេរិក។

បុរសខ្មែរក្រោមរូបនេះដដែល បានឲ្យដឹងផងដែរថា នៅខេត្តឃ្លាំងមិនដូចខេត្តព្រះត្រពាំងទេ គឺគេហៅចៅអធិការ១ព្រះអង្គ និងគណៈកម្មការវត្ត៥រូប ទៅសិក្សាតាមមន្ទីរខ្លះ គេប្រាប់ថា ដល់យើងត្រឡប់ទៅកន្លែងវិញ យើងត្រូវហៅព្រះសង្ឃក្នុងវត្តទាំងអស់ ត្រូវតែខិតខំសិក្សារៀនសូត្រ កុំជឿអ្នកនៅក្រៅប្រទេសឃោសនា នាំឲ្យមានការអុកឡុកក្នុងប្រទេស។

លោកបានឲ្យដឹងទៀតថា អាជ្ញាធរយួន គេបង្គាប់ព្រះសង្ឃ និងក្រុមសិក្ខាកាមខ្មែរក្រោម ទាំងនោះថា ព្រះពុទ្ធសាសនាខ្មែរនៅភាគខាងត្បូងអត់ល្អទេ កំពុងតែធ្វើនយោបាយសហការជាមួយនឹងអ្នកនៅក្រៅប្រទេស ដើម្បីផ្តួលរំលំរដ្ឋាភិបាលយួន និងទាមទារសិទ្ធិសេរីភាព ដែលបានបាត់បង់ទៅហើយនោះ។ ហើយគេបានបង្គាប់ក្រុមសិក្ខាកាមខ្មែរក្រោម កុំឲ្យជឿតាមព្រះសង្ឃខ្មែរ នៅភាគខាងត្បូងច្រើនប្រើនយោបាយយ៉ាងនេះ។

បុរសខ្មែរកម្ពុជាក្រោមរូបនេះ ក៏បានជម្រាបបន្ថែមទៀតផងដែរថា រដ្ឋអំណាចយួន គេមិនបានកោះអញ្ជើញជនជាតិយួន ឲ្យមកចូលរៀនអំពី គោលនយោបាយនេះជាមួយនឹងព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរក្រោមទេ គឺគេបើកបង្រៀនចំពោះតែព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរក្រោមប៉ុណ្ណោះ។

យោងតាមប្រភពដដែល ក៏ដូចជាប្រភពផ្សេងៗទៀត បានឲ្យដឹងស្រដៀងគ្នាថា គោលនយោបាយដែលចាប់បង្ខំព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរក្រោម ឲ្យទៅសិក្សារៀនសូត្រអំពីនយោបាយគុម្មុយនីស្ត តាមផ្នត់គំនិត ហូ ជីមិញ របៀបនេះ គឺគេធ្វើឡើងស្ទើរតែរៀងរាល់ឆ្នាំ ហើយខ្លឹមវាមិនខុសពីគ្នាទេ។ អាជ្ញាធរយួនចង់ធ្វើយ៉ាងណា ឲ្យវិស័យព្រះពុទ្ធសាសនាខ្មែរក្រោមដើរតាមគោលនយោបាយនេះ។ រីឯខ្មែរក្រោម ទាំងនៅក្នុងស្រុក ទាំងនៅក្រៅស្រុកមិនសប្បាយចិត្តចំពោះទង្វើបែបនេះរបស់អាជ្ញាធរយួននោះទេ ផ្ទុយទៅវិញពួកគេមានការបារម្ភយ៉ាងខ្លាំងថា នឹងមានផលប៉ះពាល់វិស័យព្រះពុទ្ធសាសនាខ្មែរក្រោម។ VOKK

---

**តពីទំព័រ១២** ធ្វើឲ្យព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរក្រោមនៅក្រៅស្រុក កើតទុក្ខមិនសុខចិត្ត ចំពោះអំពើអមនុស្សធម៌ រើសអើងពូជសាសន៍ពីសំណាក់អាជ្ញាធរយួន ដែលគ្រប់គ្រងទឹកដីខ្មែរ ប្រជាពលរដ្ឋខ្មែរ ហើយថែមទាំងបំបិទសិទ្ធិសេរីភាពខ្មែរជនជាតិដើម ម្ចាស់ទឹកម្ចាស់ដីថែមទៀត។ ហើយទង្វើទាំងនេះបានធ្វើឲ្យខ្មែរក្រោមនៅក្រៅស្រុកយល់ឃើញថា ជាការកាត់ផ្តាច់ចំណងទាក់ទងរវាងខ្មែរនៅកម្ពុជាក្រោម និងនៅកម្ពុជា ជាពិសេសវិស័យវប្បធម៌ អក្សរសាស្ត្រ និងព័ត៌មានសំខាន់ៗពីទឹកដីកម្ពុជា។

តាមរយៈការសម្ភាសន៍ ជាមួយសហការីនៃកម្មវិធីសម្លេងខ្មែរកម្ពុជាក្រោម ព្រះតេជព្រះគុណ ចន្ទ សុជាត ប្រធានសម្ព័ន្ធសមណនិស្សិត - និស្សិតខ្មែរកម្ពុជាក្រោមបានសំដែងការសោកស្តាយ និងចាត់ថាជាការប្រកាន់ពូជសាសន៍។ ព្រះអង្គក៏បានមានសង្ឃដីកាបន្ថែមថា សម័យនេះប្រព័ន្ធផ្សព្វផ្សាយគួរតែបើកទូលាយ ហើយរាល់កម្មវិធីផ្សាយ ពីទូរទស្សន៍កម្ពុជាមិនមែនខុសច្បាប់នោះទេម្យ៉ាងទៀតកម្ពុជាក៏ជាមិត្តភាពម៉ឺនឆ្នាំនឹងគ្នាទៀតផង បើសិនជាអាជ្ញាធរយួនធ្វើរបៀបនេះ គឺយួនចាត់ទុកថាកម្ពុជានេះ មិនមែនជាមិត្តដ៏ល្អជាមួយខ្លួននោះទេ។ VOKK

# ព្រះមហាក្សត្រខ្មែរអំពាវនាវសុំឲ្យបារាំងបន្តជួយកម្ពុជា



ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហមុនី [ជួរមុខ ឆ្វេង] និងនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋបារាំង លោក ហ្វ្រង់ស្វ័រ ហ្វីយ៉ុង (Francois Fillon) [មុខ ស្តាំ] ក្នុងពិធីបិទការដ្ឋានជួសជុលប្រាសាទបាពួន នៅខេត្តសៀមរាប កាលពីថ្ងៃទី៣ កក្កដា ឆ្នាំ២០១១។ RFA/Hang Savyouth

ព្រះមហាក្សត្រខ្មែរ បានអំពាវនាវចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និងរដ្ឋាភិបាលនៃប្រទេសជាមិត្តនានាក្នុងពិភពលោក សូមឱ្យបន្តជួយឧបត្ថម្ភជាថវិកា និងបច្ចេកទេសទៅទៀត ដើម្បីរៀបចំ និងជួសជុលរមណីយដ្ឋានប្រាសាទបូរាណខ្មែរដែលកំពុងទទួលរងការបាក់បែក ឱ្យល្អឡើងវិញ។

ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហមុនី និងលោក ហ្វ្រង់ស្វ័រ ហ្វីយ៉ុង (Francois Fillon) នាយករដ្ឋមន្ត្រី នៃរដ្ឋាភិបាលសាធារណរដ្ឋបារាំង បានយាង និងអញ្ជើញធ្វើជាព្រះរាជអធិបតី និងអធិបតី ក្នុងពិធីបិទការដ្ឋានជួសជុលប្រាសាទបាពួន នៅក្នុងបរិវេណអង្គរធំ នៃខេត្តសៀមរាប កាលពីថ្ងៃទី៣ខែកក្កដានេះ បន្ទាប់ពីក្រុមអ្នកបុរាណវិទ្យា របស់សាលាបារាំងចុងបូព៌ា បានជួសជុលប្រាសាទនេះ អស់រយៈពេលជាង ១៥ឆ្នាំមកហើយ ដោយចំណាយទឹកប្រាក់លើគម្រោងអស់ប្រមាណ ១០លានអឺរ៉ូ។

លោក ហ្វ្រង់ស្វ័រ ហ្វីយ៉ុង បានថ្លែងនៅក្នុងពិធីបិទការដ្ឋានជួសជុលនោះថា ការបញ្ចប់ការដ្ឋានជួសជុលប្រាសាទបាពួន គឺជាជោគជ័យមួយដែលពង្រឹង និងធ្វើឱ្យស្អិតស្អែរនូវចំណងមិត្តភាពដ៏យូរលង់រវាងព្រះរាជាណាចក្រកម្ពុជា និងបារាំង។ លោកបានមានប្រសាសន៍ទៀតថា ការជួសជុលប្រាសាទបាពួននេះ គឺជាការងារដ៏ពិបាកដែលត្រូវអត់ធ្មត់ជាទីបំផុត។

កាលពីជាង១៥ឆ្នាំមុន ដែលលោកនៅជារដ្ឋមន្ត្រីក្រសួងឧត្តមសិក្សា និងស្រាវជ្រាវ លោកបានគាំទ្រ ដល់ការចាប់ផ្ដើមការដ្ឋានជួសជុលប្រាសាទបាពួន ដ៏លំបាកមួយនេះ ហើយវាគឺជាសេចក្ដីរំភើបជាទីបំផុតមួយដែល ១៥ឆ្នាំក្រោយមក រូបលោកបានមកចូលរួមបិទការដ្ឋានជួសជុលនេះជាមួយព្រះមហាក្សត្រខ្មែរ។

លោក ហ្វ្រង់ស្វ័រ ហ្វីយ៉ុង ថ្លែងបន្ត ៖ «ការងាររស្រង់ថ្ម ចុះលេខប្រមែប្រមូលនូវរាល់ដុំថ្មផ្គុំវាឡើងវិញម្ដង១ដុំៗ បានសម្រេចរួចរាល់ដោយសារការងាររបស់លោក ប៉ាស្កាល់ រ៉ូយែរ៍ និងក្រុមការងារ ដែលធ្វើការជាមួយលោករួមជាមួយបុគ្គលិកខ្មែរជាច្រើន នាក់ផ្សេងទៀត ជាអាទិមានកម្មករលើកដី កម្មករសំណង់ ជាងកាត់ថ្ម ជាងចម្លាក់ មេការកម្មករ ស្ថាបត្យករដែល

បានរួមចំណែកធ្វើឱ្យការងារនេះ ទទួលជោគជ័យ ហើយសុទ្ធសឹងតែជាអ្នកដែលទទួលបន្ទុំជាខ្ញុំសូមសម្តែងការកោតសរសើរ ដ៏ស្មោះស្ម័គ្រនៅថ្ងៃនេះ ហើយការជួសជុលប្រាសាទបាពួននេះ ជាគម្រោងជួសជុលប្រាសាទមួយដ៏ធំនៅក្នុងពិភពលោក ហើយក៏ជាកិច្ចសហប្រតិបត្តិការបារាំង-កម្ពុជាមួយដ៏ល្អជាងគេក្នុង វិស័យបុរាណវិទ្យា»។

លោកនាយករដ្ឋមន្ត្រី នៃរដ្ឋាភិបាលបារាំង បានឱ្យដឹងថា ក្នុងរយៈពេលជាង ២០ឆ្នាំចុងក្រោយនេះ ស្ថាប័នបារាំងជាច្រើនបានផ្តល់ជំនួយដែលមានទឹកប្រាក់សរុបជាង ២០លានអឺរ៉ូ ដើម្បីធ្វើការជួសជុលប្រាង្គប្រាសាទអង្គរ និងចែករំលែក នូវចំណេះដឹងខាងវិទ្យាសាស្ត្របច្ចេកទេស និងគតិយុត្តិដល់ប្រជាពលរដ្ឋកម្ពុជា ដែលជាតម្រូវការក្នុងការថែរក្សាបេតិកភណ្ឌដ៏វិសេសវិសាលនេះ។

ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហមុនី បានមានព្រះរាជបន្ទូលថា ព្រះអង្គសូមឧទ្ទិសប្រាសាទបាពួន ឱ្យក្លាយទៅជានិមិត្តរូបនៃកម្លាំងសាមគ្គីភាព មិត្តភាព សន្តិភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជាតិកម្ពុជា និងបារាំង រួមទាំងប្រជាជាតិទាំងអស់នៅលើសកលលោក។

ព្រះមហាក្សត្របានអំពាវនាវដូច្នេះ៖ «ខ្ញុំសូមអំពាវនាវជាថ្មី ចំពោះរដ្ឋាភិបាលនៃប្រទេសបារាំង និងប្រទេសនានាជាមិត្ត សូមបន្តជួយឧបត្ថម្ភគាំទ្រ និងរៀបចំរមណីយដ្ឋានប្រាសាទបុរាណខ្មែរឡើងវិញ នៅទូទាំងប្រទេសក្នុងស្មារតីសហប្រតិបត្តិការរួម ដើម្បីការពារបេតិកភណ្ឌប្រវត្តិសាស្ត្រ ដែលជាសម្បត្តិវប្បធម៌រួម របស់មនុស្សជាតិ»។

ប្រាសាទបាពួន គឺជាប្រាសាទភ្នំដែលកសាងឡើងនៅពាក់កណ្តាលសតវត្សទី១១ ក្នុងរជ្ជកាលព្រះមហាក្សត្រខ្មែរ ព្រះបាទ ឧទ័យាទិត្យវរ្ម័ន។

រដ្ឋាភិបាលបារាំង បានឱ្យដឹងថា ចាប់តាំងពីអំឡុងទសវត្សរ៍១៩០០ សាលាបារាំងចុងបូព៌ា បានចាត់វិធានការជាច្រើនដើម្បីកាប់ឆ្ការព្រៃដ៏ក្រាស់ឃ្មឹក ដែលគ្របដណ្តប់ប្រាសាទនេះឱ្យបានស្អាតឡើងវិញ ព្រមទាំងបានកែលម្អប្រព័ន្ធបង្ហូរទឹកចេញពីប្រាសាទនេះផង។

កាលពីអំឡុងទសវត្សរ៍ទី៦០ ប្រទេសបារាំង បានចាប់ផ្តើមគម្រោងជួសជុលប្រាសាទបាពួន ម្តងមកហើយ ប៉ុន្តែបានអាក់ខានទៅវិញនៅអំឡុងទសវត្សរ៍ទី៧០ ដោយសារប្រទេសខ្មែរមានសង្គ្រាមស៊ីវិល ហើយនៅពេលដែលពួកខ្មែរក្រហមដណ្តើមកាន់កាប់អំណាច បានធ្វើឱ្យឯកសារដែលជួលជុលប្រាសាទបាពួន ទាំងអស់បានបាត់បង់ទាំងស្រុង៕

ប្រភព៖ RFA/Khmer

# ខ្មែរកម្ពុជាក្រោមជានរណា? (ត)

នៅកណ្តាលសតវត្សរ៍ទី៨ នៃអាណាចក្រចេនឡាបានចុះខ្សោយ ពីព្រោះមានការបែកបាក់ផ្ទៃក្នុងយ៉ាងត្រណម ជាហេតុធ្វើឲ្យជនជាតិជិតខាងមើលងាយ។ ឆ្លៀតឱកាសនោះពួកចោរសមុទ្រ(ជ្វា) បានចូលមកវាតត្បាតដុតបំផ្លាញទីក្រុង ឡោមព័ទ្ធរាជវាំង រហូតដល់ចាប់បានព្រះមហាក្សត្រសោយរាជ្យ មហិបតិវរ្ម័ន ហើយកាត់ព្រះសិរសាទៅថ្វាយស្តេចជ្វាថែមទៀត។

**យុគសម័យអង្គរ**

ឆ្នាំ៨០២ បានបើកយុគសម័យថ្មីមួយនៃប្រទេសកម្ពុជា ដែលឥឡូវនេះបានទទួលយ៉ាងសុះសាយថា ជាសម័យអង្គរ ឬសម័យមហានគរ។ ក្នុងអំឡុង៦សតវត្សរ៍ដ៏រុងរឿង សម័យអង្គរ គួរកត់សម្គាល់ជាងគេ គឺរជ្ជកាលនៃមហាក្សត្រទាំង៦ព្រះអង្គគឺព្រះបាទ ៖

១/ **ជ័យវរ្ម័នទី២** (៨០២-៨៥០) ជាស្ថាបនិកព្រះរាជាណាចក្រយុគសម័យអង្គរ។

ព្រះបាទ **ជ័យវរ្ម័នទី២** ដោយបានអះអាងថា ជាអ្នកបន្តខ្សែពូជពង្សនៃហ្វូណនបានឡើងសោយរាជ្យ ហើយបានបង្រួបបង្រួមជាតិឡើងវិញ នៅស្ទើរគ្រប់កន្លែងទាំងអស់ ធ្វើឲ្យព្រះរាជាណាចក្រមានឥទ្ធិពលទូទាំងអាស៊ីភាគអាគ្នេយ៍។

២/ **ឥន្ទ្រវរ្ម័នទី១** (៨៧៧-៨៨៩) ជាអ្នកផ្តើមឲ្យមានការគោរពបូជាបុព្វបុរស។ ទ្រង់បានកសាងបារាយណ៍ទឹក និងប្រាសាទជាច្រើន រួមមានប្រាសាទព្រះគោ ដើម្បីឧទ្ទិសថ្វាយចំពោះបុព្វបុរសព្រះអង្គ។ នេះជាលើកដំបូងក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលគេមានឯកសារជាក់លាក់ ពីការគោរពបូជាបុព្វបុរសរបស់ព្រះរាជា ដែលត្រូវលើកតម្កើង ឲ្យមានឋានៈស្មើនឹងទេវ-ទេវី។ ខ្មែរយើងនៅរក្សាទម្លាប់ដល់សព្វថ្ងៃ ជាពិសេសក្នុងការប្រារព្ធបុណ្យសែនដូនតា (បុណ្យភ្ជុំបិណ្ឌ)។

៣/ **យសោវរ្ម័នទី១** (៨៨៩-៩១៥) ទ្រង់ជាស្ថាបនិកទី១ នៃក្រុងអង្គរ(យសោធរៈបុរៈ) ដែលស្ថិតនៅជារាជធានីរបស់ខ្មែរ អស់រយៈកាល៦សតវត្សរ៍។ ក្នុងការកសាងរាជធានីថ្មី ព្រះបាទយសោវរ្ម័នទី១ ទ្រង់បានឲ្យកសាងអាស្រមជាច្រើនសម្រាប់គណៈសាសនាផ្សេងៗ។

បុរាណវិទូជាតិបារាំង បានរកឃើញរូបចម្លាក់ព្រះសីវៈ វិស្ណុ និងព្រះពុទ្ធរូបកសាងពីសំរិទ្ធ ក្នុងសម័យនោះ នៅវត្តពោធិសេរី (កំពង់ស្ពាន) និងក្នុងវត្តផ្សេងៗទៀតទូទាំងដែនដីសណ្តទន្លេមេគង្គ។

៤/ **សូរ្យវរ្ម័នទី១** (១០០២-១០៥០) ជារាជវង្សខ្មែរ នៃជំនាន់អាណាចក្រភ្នំ ទ្រង់បានភៀសខ្លួនទៅនគរជ្វា ពេលដែលទ័ពចេនឡាចូលវាយលុក។ ព្រះអង្គជាព្រះរាជាទី១នៃយុគសម័យអង្គរ ដែលកាន់ពុទ្ធសាសនាមហាយាន។

៥/ **សូរិយាវរ្ម័នទី២** (១១១៣-១១៥០) ជាស្ថាបនិកនៃអង្គរវត្ត(ទី២)

ព្រះបាទ**សូរិយាវរ្ម័នទី២** មានស្នាព្រះហ

ស្តធំៗបីគឺ ៖

១) កសាងប្រាសាទអង្គរវត្តនិងបន្តការស្ថាបនាប្រាសាទព្រះវិហារ

២) បង្រួបបង្រួមសង្គមផ្ទៃក្នុង

៣) តម្កើងអានុភាពខ្មែរ លើឆាកអន្តរជាតិ ដោយលើកទ័ពទៅវាយជាមួយប្រទេសជិតខាង ដែលមានយួន( Dai Viet) ចាម និង មនជាដើម។

នៅកម្ពុជាក្រោម ព្រះអង្គបានបញ្ជាឲ្យសង់នូវបន្ទាយយ៉ាងច្រើន សម្រាប់ត្រួតត្រាដែនដី មានបន្ទាយពាមត្រួតត្រាដោយ **ពញាមាស**, បន្ទាយពាមមេគង្គ ត្រួតត្រាដោយ **ពញាប្រែង**, បន្ទាយព្រៃនគរត្រួតត្រាដោយ **ពញាឌិន** (មកពីប្រភពនេះហើយ ទើបពួកយួនប្រែឈ្មោះម្តុំព្រៃនគរទៅជា **យ៉ាឌិន** (Gia Dinh)។

៦/ **ជយវរ្ម័នទី ៧** ( ១១៨១-១២១៩) ជាស្ថាបនិកអង្គរទី៣ (អង្គរធំ)។

ព្រះអង្គម្ចាស់ **ជ័យវរ្ម័ន** ជាអ្នកយុទ្ធសាស្ត្រផ្នែកយោធាដ៏ចំណាប់មួយព្រះអង្គដែលបានដឹកនាំកងទ័ពប្រយុទ្ធ ដើម្បីរំដោះទឹកដីឲ្យផុតពីការត្រួតត្រារបស់បរទេស។ ក្រោយពីដេញទ័ពឈ្លានពានរបស់ចាម ផុតពីទីក្រុងអង្គរ ហើយទើបព្រះអង្គឡើងសោយរាជ្យក្នុងព្រះជន្មាយុ៥៦ឆ្នាំមានព្រះនាមជាជ័យវរ្ម័នទី៧។

**ជ័យវរ្ម័នទី៧** ជាអធិរាជ ដែលបានស្ថាបនារាជធានីអង្គរទី៣ ឬអង្គរធំ និងប្រទេសជាតិទាំងមូល ដែលមានទំហំទូលំទូលាយជាងពេលណាៗទាំងអស់។ ប្រទេសខ្មែរសម័យនោះបានត្រួតត្រាតាំងពី ភូមា រហូតដល់មួយផ្នែកនៃ ម៉ាឡេស៊ី។ ព្រះអង្គក៏ជាអ្នកកសាង សមិទ្ធផលច្រើនជាងគេបំផុត។

ទេពកោសល្យរបស់ព្រះបាទ **ជ័យវរ្ម័នទី៧** គឺទ្រង់ចេះសម្របសម្រួល អ្វីដែលជារបស់សាសនា មានពីមុន (ប្រាសាទភ្នំ) និងធ្វើអ្វីដែលជាថ្មី ដើម្បីឲ្យបានពេញចិត្តទាំងពួកព្រាហ្មណ៍ទាំងពួករាស្ត្រ។ ព្រះអង្គថែមទាំងមានព្រះរាជហឫទ័យគិតគូដល់សុខមាលភាពរបស់ប្រជារាស្ត្រផង។ សិលាចារឹកតាព្រហ្ម បានឲ្យដឹងពីការកសាងនូវមន្ទីរពេទ្យ នៅពាសពេញផ្ទៃប្រទេស សម្រាប់ព្យាបាលមនុស្សម្នា ដោយមិនប្រកាន់វណ្ណៈក្នុងសង្គមឡើយ។

តាំងពីរជ្ជកាលព្រះបាទ **ជយវរ្ម័នទី៧** មកពុទ្ធបរិស័ទបានកសាងវត្តយ៉ាងច្រើន នៅគ្រប់ខេត្តនៃកម្ពុជាក្រោម។ នៅខេត្តឃ្លាំងមានវត្តប្រាសាទគង់ (១២២៤) វត្តចតុមុខារតនរាម-ជ្រោយទឹម(១៤៦៥)វត្ត ពោធិព្រឹក្ស-ព្រៃកគយ(១៤៦២) វត្តឃ្លាំង(១៥៣៣)។ល។ នៅព្រះត្រពាំងមានវត្តភិរម្យរាជ្យ (១០៧៩) វត្តមជ្ឈិមារាម (១៣១៧)។ល។

ការពង្រីកដែនដី បានត្រូវចុះថយបន្តិចម្តងៗ មកពីការឈ្លានពានពីពួកម៉ុងហ្គោល (Mongol) សៀម (Thai) ,ចាម (Cham) និងក្រោយមកមានយួន(Viet Nam)ផង។

ឆ្នាំ១៤៣១ ព្រះបាទ **ពញាយ៉ាត** ត្រូវបង្ខំ

បោះបង់ក្រុងអង្គរចោល ហើយបានរើរាជធានីមកតាំងនៅភ្នំពេញវិញ។

ព្រះរាជាណាចក្រកម្ពុជា ចេះតែចុះអន់ថយជាលំដាប់ ពីព្រោះអ្នកដឹកនាំខ្មែរអន់ខ្សោយផង និងមកអំពីយុទ្ធសាស្ត្រលេបទឹកដីខ្មែរពីប្រទេសជិតខាងផង។

### យុគសម័យ យួនជ្រៀតជ្រែកមកលើទឹកដីខ្មែរ តាំងពី ស.វ.ទី១៧

ឆ្នាំ១៦២០ អាចចាត់ទុកជាតំណាក់កាលមួយ ដែលចាប់ផ្ដើមនូវកម្មវាសនាដ៏អភ័ព្វចំពោះខ្មែរកម្ពុជាក្រោមយើង។

ព្រះបាទ**ជ័យជេដ្ឋាទី២** (១៦១៨-១៦២៨) ដែលធ្លាប់បានរស់នៅប្រទេសសៀម បានងាកមកចងមេត្រីភាពជាមួយប្រទេសយួន (An Nam) ដែលកំពុងតែអនុវត្តផែនការ វាតទីមកទិសខាងត្បូង (Nam Tien) របស់គេ។

សាស្ត្រាចារ្យខ្មែរក្រោមម្នាក់គឺលោក **ត្រឹង ង៉ា** បានសរសេរយ៉ាងសង្ខេបអំពីយួនដូចខាងក្រោម ៖

"ក្រោយពីបានរំដោះខ្លួន ចេញផុតអំពីនឹមចិន អស់រយៈពេលជាងមួយពាន់ឆ្នាំមក (១១១ មុនគ.ស. គ.ស.៩២១) ស្ដេចយួនក្នុងរាជវង្ស **លី** (Ly) បានផ្ដើមវាយលុកប្រទេសចម្ប៉ាចាប់តាំងពី ស.វ.ទី១១ តទៅ។ នៅ គ.ស.១៤៧០ ស្ដេចយួនព្រះនាម **ឡេ ថាញ់ តុង** (Le Thanh Ton) ទ្រង់វាយយកបានរាជធានីវិជ័យរបស់ចាម ដែលនៅពេលនោះ មានពលទាហានស្លាប់ដល់ទៅ ៤ម៉ឺននាក់។ ជោគជ័យដ៏ធំសម្បើមរបស់ជនជាតិយួន បានរុញច្រានព្រំប្រទល់ប្រទេស ចម្ប៉ាចុះឆ្ងាយមកទិសខាងត្បូងទៀត គឺមកទល់ជ្រោយ Varrella។ នៅ គ.ស. ១៦០០ ប្រទេសយួនត្រូវបាត់បង់ឯកភាពរបស់ខ្លួន ៖ ទឹកដីត្រូវបែងចែកជាពីរ ខាងជើងជារបស់**រាជវង្សឡេ** (Le) ដែលមានពួកស្ដេចត្រាញ់ **ទ្រិញ** (Trinh) ជាអ្នកគាំទ្រខាងត្បូង ត្រូវបានទៅពួកស្ដេចត្រាញ់**ង្វៀង** (Nguyen)។ ប៉ុន្តែទោះជាមានវិបត្តិផ្ទៃក្នុងក៏ដោយ ក៏ពួក **ង្វៀង** បានបន្តវាយដណ្ដើមយកទឹកដីប្រទេសចម្ប៉ាទាល់តែអស់រលីង។ (គួរគប្បីកត់សម្គាល់ថា យួនប្រើយុទ្ធសាស្ត្រដូចគ្នា សម្រាប់បំបាត់ពូជសាសន៍ចាម (ស.វ. ទី១១-ស.វ.ទី១៧) និងខ្មែរ (ស.វ. ទី១៧-ដល់សព្វថ្ងៃ)។ យុទ្ធសាស្ត្រដែលយួនហៅថា ផែនការវាតទីមកទិសខាងត្បូង (Nam Tien) សំអាងទៅលើកលល្បិចពីរយ៉ាងគឺ៖

១/នយោបាយចំណងមេត្រីភាព បង-ប្អូន (Tinh Huu Nghi Anh Em) និង

២/នយោបាយអន្តោប្រវេសន៍ (Dan Di Truoc Nha Nuoc Di Sau)។

ឆ្នាំ ១៣០៦ ស្ដេចចាម **ជ័យសង្ហវរ្ម័នទី៣** (Jaya Simhavarman III, យួនហៅ Che Man)បានរៀបអភិសេកជាមួយម្ចាស់ក្សត្រីយ៍យួន **ហ្វៀង ត្រឹង** (Huyen Tran Cong Chua)។ ជាថ្នូរនៃអាពាហ៍ពិពាហ៍នេះ ស្ដេចចាមប្រគល់ដីពីរខេត្តឲ្យយួន បើកផ្លូវឲ្យយួនលេបប្រទេសចម្ប៉ាទាំង

មូល។

ឆ្នាំ១៣០៦ស្តេចខ្មែរព្រះបាទ **ជ័យជេដ្ឋាទី២** បានរៀបអភិសេកជាមួយម្ចាស់ក្សត្រីយ៍យួន **ង្វៀង ផុក ង៉ុក វ៉ាង** (Nguyen Phuc Ngoc Van) ជាកូនស្តេចត្រាញ់យួន **ង្វៀង ផុក ង្វៀង** (Chua Sai Nguyen Phuc Nguyen) គឺស្តេច (Hy Tong)។ ជាចំណងដៃឪពុកក្មេក បានជូនកូនប្រសានូវនារីកិត្តិយសចំនួន៥០០នាក់ និងបុរសកិត្តិយស ៥០០នាក់ ដង្ហែព្រះអង្គម្ចាស់ក្សត្រិយ៍យួនមកព្រះរាជធានីឧត្តុង្គ។ ដោយស្រឡាញ់ប្រពន្ធស្អាត ហើយយល់ច្រឡំថាយួនមានចិត្តល្អ និងសុភាពរាក់ទាក់ផង ព្រះបាទ **ជ័យជេដ្ឋាទី២** បានអនុញ្ញាតឲ្យយួនចូលមករកស៊ី នៅតំបន់ព្រះសួគ៌ា (Ba Ria) ត្រពាំងចង្វា (Bien Hoa) និងវាលប្រើស(DongNai)។ នេះជាលើកទីមួយបើកផ្លូវឲ្យយួនរំកិលចូលដីខ្មែរបន្តិចម្តងៗ។

ឆ្នាំ ១៦២៣ ដោយការយោគយល់ដល់អគ្គមហេសី ព្រះបាទ **ជ័យជេដ្ឋាទី២** ទ្រង់បានអនុញ្ញាតឲ្យ ក្រុងហ្វេ(Hue) កាន់កាប់ក្រសួងគយនៅព្រៃនគរនិងវាលប្រើស (Dong Nai)។ ប្រជារាស្ត្រយួន ក៏ដឹកកូនជញ្ជូនចៅបបួលគ្នាចូលទៅក្នុងទឹកដីខ្មែរកាន់តែច្រើន។ ចំណែកជនជាតិខ្មែរវិញ ត្រូវបង្ខំចិត្តលះបង់ចោលទ្រព្យសម្បត្តិស្រុកភូមិថយទៅនៅកន្លែងផ្សេង ព្រោះពុំអាចតស៊ូរស់នៅជាមួយពួកចំណូលថ្មីបាន។

ឆ្នាំ ១៦២៤ ព្រះមហាក្សត្រីយានីខ្មែរកំណើតយួន (ខ្មែរហៅថា ព្រះអង្គចូវ) បានប្រសូតបុត្រីមួយ ព្រះនាម **អង្គញ៉ា** ក្សត្រីមួយ។

ឆ្នាំ ១៦៣៨ ព្រះអង្គ **ទងរាជា** ទ្រង់បានទាមទារយកដី ព្រៃនគរ-កំពង់ក្របី (Ben Nghe) មកវិញ ប៉ុន្តែអគ្គមហេសីយួនរបស់ ព្រះបាទ **ជ័យជេដ្ឋាទី២** ទ្រង់បានស្នើឲ្យពន្យាពេលឲ្យបានយូរបន្តិចទៀត។ បន្តមកដោយខ្មែរចេះតែមានការបែកបាក់គ្នា ទើបយួនយកមកកម្ពុជាក្រោមទាំងអស់។

*Tu do cu vai nam lai co chuyen cuop ngoi, tranh gianh thien ha giua hoang toc Chan lap, quan nha nguyen phai sangcuu vien, sap dat trat tur. Va moi lan can thiep nhu the, vua Mien lai cat dat den on, cho den... tat ca phan dat mien nam thuoc ve nguoi Viet.

*(Le Huong, nguoi Viet goc Mien)*

ឆ្នាំ១៦៥៨ ព្រះអង្គ **សូរ** និងព្រះអង្គ **តន** ពីរនាក់បងប្អូនបង្កើត (កូនរបស់ព្រះឧទ័យ) រត់ទៅពឹងពាក់យួន ដើម្បីប្រឆាំងនឹងបងប្អូនជីដូនមួយគឺ **ចៅពញាច័ន្ទ** (ជាកូនរបស់ ព្រះបាទជ័យជេដ្ឋាទី២)។ ឆ្លៀតឱកាសដ៏ល្អនេះស្តេចយួន **ហៀង វឿង** (Hien Vuong Nguyen Phuc Tan) បានបញ្ជាឲ្យលើកទ័ព ៣០០០ នាក់ចូលមកស្រុកខ្មែរ។

លុះបានជ័យជម្នះលើ **ចៅពញាច័ន្ទ** ហើយយួនបែរមកវាយព្រះអង្គ **សូរ** និងព្រះអង្គ **តន** វិញ ។ ទ័ពខ្មែរបានវាយឈ្នះដេញទ័ពយួនទៅស្រុកវិញ។ រួចមក ព្រះអង្គ **តន** នៅត្រួត

ព្រៃនគរផ្ទាល់ព្រះអង្គ។

ឆ្នាំ១៦៧៩ នាម៉ឺនភៀសខ្លួននៃជនជាតិចិនពីរនាក់ នាំទ័ពនិងប្រជាជនចិន៣០០០នាក់ មកជ្រកកោននៅ ព្រៃនគរ និងមេ ស (My Tho) បង្កើតទីក្រុង មានឈ្មួញបរទេសដូចជា ជ្វា ជប៉ុន និង អឺរ៉ុប យ៉ាងច្រើនកុះករ។ នៅក្នុងដំណាក់កាលនោះដែរ មានចិនម្នាក់ទៀតឈ្មោះ **ម៉ាក គីវ** (Mac Cuu) ក៏រត់មកជ្រកកោននឹងស្តេចខ្មែរ ហើយបានតែងតាំងជាមន្ត្រីត្រួតត្រាតំបន់ឆ្នេរឈូងសមុទ្រសៀម (Ha Tien) កោះត្រល់ (Phu Quoc) ក្រមួនស (Rach Gai) ទឹកខ្មៅ (Ca mau) កំពត និងកំពង់សោម។

នៅឆ្នាំបន្តបន្ទាប់ តែងតែកើតឡើងជារឿយៗ នូវវិបត្តិក្នុងរាជវង្សានុវង្សអំពើក្បត់របស់មន្ត្រី និងការសូមជំនួយពីបរទេស ដែលជាហេតុនាំឲ្យយួន លេបយកទឹកដីកម្ពុជាក្រោមជាបន្តបន្ទាប់។

ឆ្នាំ១៦៩៨ឧត្តមសេនីយ៍ខ្មែរ **នរោមអ៊ុម** ដោយមានការគាំទ្ររបស់ទ័ពយួនផង បានបះបោរប្រឆាំងនឹងព្រះបាទ **ជ័យជេដ្ឋាទី៤**។ ទ័ពរបស់ស្តេចខ្មែរ បានវាយតបវិញនៅម៉ុព្រៃនគរ ហើយចាប់ **នរោមអ៊ុម** យកទៅកាត់ក្បាល។ ក្រោយពីជ័យជម្នះនោះព្រះអង្គក៏នាំ ទ័ពវិលទៅឧត្តុង្គវិញ។

ឆ្នាំ១៧១៤ **ម៉ាក គីវ** (Mac Cuu) បែរជាប្រគល់ទឹកដីខ្មែរ ដែលនៅក្រោមអំណាចរបស់គាត់ទៅឲ្យអធិរាជយួនវិញ។

ឆ្នាំ១៧៣០ ខ្មែរក្រោកឡើងវាយយួននៅម៉ុព្រៃនគរ។ ព្រះមហាក្សត្រខ្មែរមិនបានចូលរួមទេ ហើយថែមទាំងបញ្ជូនទ័ពទៅវាយបំបែកក្រុមនេះទៀត។ កងទ័ពរបស់អធិរាជយួន **និនវឿង** (Ninh Vuong-Nguyen Phuc Thu) បានវាយតបហើយបោះទីតាំងនៅ មេ ស (Ninh Tho) លង់ហោរ (Long ho គឺ Vinh Long)។

ឆ្នាំ១៧៣៩ **ព្រះធម្មរាជាទី៣**លើកទ័ពមកវាយដណ្តើមយកពាមមកវិញ ប៉ុន្តែមិនបានជោគជ័យទេ។

ពីឆ្នាំ១៧៥៦-១៧៥៨ វិបត្តិព្រះរាជវង្សខ្មែរ (អង្គអឹម និងអង្គទង) ក៏បានកើតឡើងទៀត។

ព្រះបាទ **រាមាធិបតី អង្គទង** ក៏រត់ទៅពឹងយួន **ម៉ាក តុង** នៅ ពាម (Ha Tien) ជាការតបស្នងសងគុណដែលយួនបានជួយនោះ អង្គ **ទង** បានប្រគល់ខេត្តផ្សារដែក (Sa Dec) និងមាត់ជ្រូក (Chau Doc)ឲ្យទៅស្តេច Vu Vuong-Nguyen Phuc Khoat។

ចំណែកព្រះ**ឧទ័យរាជា** អង្គ **តន** វិញ ដើម្បីសងគុណយួន ដែលបានជួយមកវាយឈ្នះខ្មែរគ្នាឯងរ ហូតបានឡើងសោយរាជ្យ បានប្រគល់ខេត្តពីរទៀតទៅឲ្យថៅហ្វាយគឺ ព្រះត្រពាំង (Tra Vinh) និងឃ្លាំង (Sac Trang)។

លោក Philippe Papin បានសរសេរថាពួកយួនយកខេត្ត រោងដំរី (Tay Ninh) នៅឆ្នាំ១៧៥០ និងទឹកដីខ្មែរទាំងអស់នៅខាងជើងទន្លេបាសាក់ (Hau Giang)។

**(នៅមានត....)**

# ទិវាបុណ្យឯករាជ្យ នៃសហរដ្ឋអាមេរិក



ទង់ជាតិសហរដ្ឋអាមេរិក

សឹងតែមួយសប្ដាហ៍កន្លងមកហើយ អ្នកដែលរស់នៅលើទឹកដីនៃសហរដ្ឋអាមេរិក បានឮសូរសម្លេងផ្ទុះ ពីទីនេះម្ដង ពីទីនោះម្ដង ទាំងថ្ងៃយប់។ នោះមិនមែនជាសូរកាំភ្លើង ដោយសារអសន្តិសុខ ដោយប្រការណាមួយទេ ប៉ុន្តែគឺសូរផាវតូចធំ ដែលអ្នកស្រុកអុជ ដើម្បីអបអរសាទរចំពោះថ្ងៃបុណ្យឯករាជ្យ នៃសហរដ្ឋអាមេរិក។ ជាប្រពៃណី ជនជាតិអាមេរិកាំងតែងប្រារព្ធពិធីនេះជារៀងរាល់ឆ្នាំ នៅថ្ងៃទី៤ ខែកក្កដា ជាថ្ងៃដែលសហរដ្ឋអាមេរិក បានប្រកាសឯករាជ្យពីចក្រភពអង់គ្លេស។ ស្មារតីស្នេហាជាតិ មាតុភូមិបានត្រូវបង្ហាញឡើង ដោយការដោតទង់ជាតិសហរដ្ឋអាមេរិក ស្ទើរតែគ្រប់មុខផ្ទះ និងនៅតាមគ្រឹះស្ថានសាធារណៈ។ ហើយពិធីអបអរសាទរក៏ត្រូវបានរៀបចំឡើងជាទូទៅ ទាំងជាផ្លូវការ និងជារបៀបគ្រួសារ។ ពិធីអបអរសាទរនេះ មានឫសគល់យ៉ាងជ្រៅ ទៅក្នុងប្រពៃណីអាមេរិកាំងអំពីសេរីភាព នយោបាយ។

តើនៅថ្ងៃបុណ្យនេះ ប្រជាពលរដ្ឋអាមេរិកាំងធ្វើអ្វីខ្លះ ?

មានមនុស្សតិចតួចណាស់ ដែលធ្វើការងារនៅថ្ងៃបុណ្យឯករាជ្យ។ គឺជាថ្ងៃដែលក្រុមគ្រួសារនាំគ្នាវេចខ្ចប់ ចំណីអាហារយកទៅតាមសួនឧទ្យានសាធារណៈ គឺថ្ងៃអាំងសាច់ទទួលទានជាការបង្ហាញអំពីការឱ្យតម្លៃយ៉ាងខ្លាំង ទៅលើទំនៀមទម្លាប់អាមេរិកាំង ចំពោះសេរីភាពនយោបាយ។ សកម្មភាពចម្រុះក្នុងទិវានេះ មានការប្រណាំងគ្នាទទួលទានផ្លែឪឡឹក ឬនុំបុ័ងសាច់ដែលហៅថា ហតដក (Hot dog) និងល្បែងកីឡាដូចជាការលេងបេសបល (Base ball) ការរត់ប្រណាំងដោយជើងបី ការហែលទឹក និងបាញ់គ្នាដោយកាំភ្លើងទឹកជាដើម។

សហគមន៍ចំនួនច្រើន បានរៀបចំពិធីអុជកាំជ្រួច កំដរដោយបទភ្លេងស្នេហាជាតិ។ កាំជ្រួចដែលល្អគួរឱ្យចាប់អារម្មណ៍ជាងគេ បានត្រូវបង្ហាញតាមកញ្ចក់ទូរទស្សន៍។ ពួកបុគ្គលិកខ្លះបានយកថ្ងៃវិស្សមកាលប្រចាំឆ្នាំរបស់គេមួយថ្ងៃមកបន្ថែមលើការឈប់សម្រាកចុងសប្ដាហ៍ បន្តសម្រាកឱ្យបានយូរ ដើម្បីគេចវេះពីសីតុណ្ហភាពរដូវក្ដៅ ទៅសម្រាកកាយនៅតាមឆ្នេរសមុទ្រ ឬនៅតាមរមណីយដ្ឋាននានា។

ទិវាឯករាជ្យ គឺជាថ្ងៃបុណ្យស្នេហាជាតិ ដើម្បីអបអរសាទរចំពោះអ្វី ដែលមានទិដ្ឋភាពជាវិជ្ជមានចំពោះសហរដ្ឋអាមេរិក។ អ្នកនយោបាយជាច្រើន បានបង្ហាញខ្លួននៅតាមទីកន្លែងដែលមាន

វិទ្យុសំឡេងកម្ពុជាក្រោម (VOKK)

សារព័ត៌មាន ព្រៃនគរ ( PNN)

វិទ្យុសំឡេងកម្ពុជាក្រោម
VOKK
VOICE OF KAMPUCHEA KROM RADIO

The Preynokor News

ការរៀបចំជាសាធារណៈ ដើម្បីបង្ហាញការគាំទ្ររបស់ខ្លួនចំពោះប្រវត្តិសាស្ត្រ មតិក និងប្រជាពលរដ្ឋក្នុងប្រទេស។ លើសពីអ្វីទាំងអស់ ប្រជាពលរដ្ឋនៃសហរដ្ឋអាមេរិក បង្ហាញនូវការដឹងគុណចំពោះសេរីភាព និងឯករាជ្យ ដែលបានមកដោយការតស៊ូរបស់មនុស្សជំនាន់ដំបូងៗ នៃសហរដ្ឋអាមេរិកបច្ចុប្បន្នកាល។

ទិវាឯករាជ្យ ជាទិវាបុណ្យរបស់ជាតិ។ ដោយសកម្មភាពមនុស្សដ៏ច្រើន បានចេញដំណើរទៅទីដៅរៀងៗខ្លួន ចរាចរក៏មានការកកស្ទះជាច្រើនកន្លែងដែរ។ រីឯប្រភពនៃការរៀបចំពិធីអបអរសាទរនេះ គឺនៅឆ្នាំ១៧៧៥ ប្រជាពលរដ្ឋនៃរដ្ឋ នូវអ៊ីនគ្លែន (New England) បានចាប់ផ្ដើមការប្រយុទ្ធ ជាមួយនឹងពួកអង់គ្លេស ដើម្បីឯករាជ្យរបស់រដ្ឋនេះ។ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៧៧៦ សភាបានបោះឆ្នោតដោយសម្ងាត់អនុម័តយកឯករាជ្យពីចក្រភពអង់គ្លេស។ ការប្រកាសឯករាជ្យ បានត្រូវធ្វើឡើងជាដំបូងពីរថ្ងៃក្រោយគឺនៅថ្ងៃទី៤ខែកក្កដា ឆ្នាំ១៧៧៦។ ការសូត្រឡើងជាលើកទី១ នូវសេចក្ដីប្រកាសឯករាជ្យ បានធ្វើឡើងនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៧៧៦។ ក្រុមប្រតិភូបានចុះហត្ថលេខាលើសេចក្ដីប្រកាសឯករាជ្យ នៅថ្ងៃទី២ ខែសីហា ឆ្នាំ១៧៧៦។ នៅឆ្នាំ១៨៧០ ទិវាឯករាជ្យបានត្រូវរៀបចំឡើង ប៉ុន្តែពួកបុគ្គលិករបស់រដ្ឋ មិនបានទទួលប្រាក់កម្រៃសម្រាប់ថ្ងៃបុណ្យនោះទេ។ គឺទាល់តែរហូតដល់ឆ្នាំ១៩៤១ ទើបពួកគេបានទទួលប្រាក់កម្រៃ សម្រាប់ឈប់សម្រាកនៅថ្ងៃបុណ្យឯករាជ្យ។

មានកំណត់សំគាល់ដ៏សំខាន់មួយ នោះគឺប្រធានាធិបតី ថូម៉ាស់ ជេហ្វឺសុន និង ចន អាដាំ ទាំងពីររូប ជាអ្នកបានចុះហត្ថលេខាលើសេចក្ដីប្រកាសឯករាជ្យ ហើយហាសិបឆ្នាំក្រោយមក



រូបសំណាកតាងសន្តិភាព នៃសហរដ្ឋអាមេរិក

លោកប្រធានាធិបតី នៃសហរដ្ឋអាមេរិកទាំងពីររូបនេះ ក៏បានធ្វើមរណកាលក្នុងថ្ងៃ-ខែ-និងឆ្នាំជាមួយគ្នា គឺនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៨២៦ ដូចគ្នា។ ក៏ជារឿងគួរកត់សំគាល់មួយទៀត គឺមានជនជាតិកំណើតដើម អាមេរិកាំងរស់នៅក្នុងប្រទេស ហើយក្រុមកុលសម្ពន្ធទាំងនេះ មានជាតិនិងរដ្ឋាភិបាលផ្ទាល់របស់ពួកគេ។ ក្រៅពីទង់ជាតិអាមេរិកាំងដែលបក់នៅតាមផ្ទះ និងតាមគ្រឹះស្ថានសាធារណៈនានា អ្វីដែលជានិមិត្តរូបនៃឯករាជ្យរបស់សហរដ្ឋអាមេរិក គឺមានរូបសំណាកដ៏ល្បីល្បាញមួយ ដែលមនុស្សម្នាក្នុងពិភពលោកតែង ប្រាថ្នាចង់ឱ្យបានទៅដល់ ឱ្យបានឃើញនិងស្ទាបអង្អែល ហើយថតរូបទុកជាអនុស្សាវរីយ៍ផងនោះ គឺរូបសំណាកតំណាងឱ្យសេរីភាពនិងឯករាជ្យ (Statue of Liberty) កសាងឡើងនៅលើកោះ អែលីស អៃឡែន (Ellis Island)

នៃទីក្រុងញូវយ៉ក។ អ្វីដែលគួរកត់សំគាល់ទៀតនោះ គឺរូបសំណាកនេះ ត្រូវបានធ្វើពីស្ពាន់សុទ្ធ ហើយមានកំពស់ជាងមួយរយម៉ែត្រ និងទម្ងន់ពីររយម្ភៃប្រាំតោន ។

ស្រាវជ្រាវដោយ **សឹង សម្រេច** VOKK នៃវិទ្យុសម្លេងកម្ពុជាក្រោមក្នុងឱកាសបុណ្យឯករាជនៃសហរដ្ឋអាមេរិក ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ពីរដ្ឋកាលីហ្វ័រនីញ៉ា នៃសហរដ្ឋអាមេរិក៕

# លិខិតរបស់អង្គការ សមាគមខ្មែរកម្ពុជាក្រោម ជូននាយករដ្ឋមន្ត្រីបារាំងក្នុងដំណើរទស្សនកិច្ចមកកម្ពុជា

ក្នុងដំណើរទស្សនៈកិច្ច រយៈពេលពីរថ្ងៃ គឺនៅថ្ងៃទី២ ទី៣ ខែកក្កដា ឆ្នាំ២០១១ នៅព្រះរាជាណាចក្រកម្ពុជា របស់នាយករដ្ឋមន្ត្រីបារាំង គឺលោក **ហ្វ្រង់ស័រ ហ្វីយ៉ុង** អង្គការ សមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជា បានធ្វើលិខិតមួយច្បាប់ផ្ញើជូនលោក ដោយស្នើសុំបង្ហាញឯកសារស្តីពីបារាំងកាត់ទឹកដីកម្ពុជាក្រោមឲ្យយួន។ លិខិតរបស់អង្គការ សមាគមខ្មែរកម្ពុជាក្រោម ដែលតំណាងដោយ មជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោម និងចុះហត្ថលេខារួមគ្នាដោយអង្គការសមាគមចំនួន៦ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១១ ផ្ញើជូនតាមរយៈឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមលិខិតអ្នកតំណាងរាស្ត្រខ្មែរចំនួន១៦រូប បានផ្ញើទៅប្រធានរដ្ឋសភា និងប្រធានាធិបតី នៃសាធារណរដ្ឋបារាំង កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩។ កម្មវត្ថុនៃលិខិត គឺសំណើសុំផ្តល់ឯកសារ ស្តីពីរដ្ឋាភិបាលបារាំងបានកាត់ទឹកដីកម្ពុជាក្រោម ឲ្យទៅវៀតណាម។ ខ្លឹមសារទាំងស្រុង នៃលិខិតនេះមានដូចតទៅ៖

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំជាអង្គការ សមាគមខ្មែរកម្ពុជាក្រោម មានកិត្តិយសសូមជម្រាបឯកឧត្តមនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ក្រុមអ្នកតំណាងរាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជាចំនួន១៦រូប បានចុះហត្ថលេខាក្នុងលិខិតមួយច្បាប់មានខ្លឹមសារដូចគ្នា ទាំងភាសាខ្មែរ និងភាសាបារាំង បានផ្ញើជូនឯកឧត្តមប្រធានរដ្ឋសភា និងឯកឧត្តមប្រធានាធិបតី តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី២ ទី៣ ខែកក្កដា ឆ្នាំ២០១១ ឯកឧត្តមនាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋបារាំងអមដំណើរដោយរដ្ឋមន្ត្រីចំនួន៤រូបទៀត នឹងមកបំពេញទស្សនកិច្ច នៅព្រះរាជាណាចក្រកម្ពុជាចំនួន២ថ្ងៃ។ ក្នុងនាមអង្គការ សមាគមខ្មែរកម្ពុជាក្រោម តំណាងឲ្យប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមទាំងព្រះសង្ឃ ទាំងគ្រហស្ថ មានសេចក្តីត្រេកអរ និងអបអរសាទរយ៉ាងក្រៃលែង ហើយសូមឯកឧត្តម មេត្តាជួយពាំនាំយក នូវឯសារ និងព័ត៌មានមួយចំនួន ដែលជាសេចក្តីត្រូវការជាចាំបាច់របស់បងប្អូន ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមផ្ញើជូនរដ្ឋាភិបាល និងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃសាធារណរដ្ឋបារាំង ដើម្បីជួយដោះស្រាយបញ្ហានៃការរំលោភសិទ្ធិមនុស្ស រំលោភសិទ្ធិជនជាតិដើម បំបិទសិទ្ធិសេរីភាព គំរាមកំហែងគ្រប់ពេលវេលា ដែលជាបញ្ហាមួយដ៏អួអាប់ជាទីបំផុតពីសំណាក់រដ្ឋាភិបាលវៀតណាម មកលើបងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅលើទឹកដីកូសាំងស៊ីន។

ទឹកដីកម្ពុជាក្រោម ជាទឹកដីមួយចំណែកនៃព្រះរាជាណាចក្រកម្ពុជា ដែលមានផ្ទៃដី

៦៨.៩៦៥ គីឡូម៉ែត្រក្រឡា មាន១៤.៧៨៨ភូមិ មាន១.៣៦៨ឃុំ មាន១៧១ស្រុក មាន២១ខេត្ត ក្រុង មានប្រជាពលរដ្ឋខ្មែរ១២លាននាក់ មានវត្ត ព្រះពុទ្ធសាសនាខ្មែរជាង៥៦៧វត្ត មានព្រះសង្ឃ ព្រះពុទ្ធសាសនាខ្មែរជាង២ម៉ឺនអង្គ។ កម្ពុជា ក្រោម មានរាជធានីមួយឈ្មោះថា **ព្រៃនគរ** បច្ចុប្បន្ន វៀតណាមបានប្ដូរឈ្មោះទៅជាភាសា វៀតណាម ដែលមានឈ្មោះថាទីក្រុង **ហូជីមិញ** ទឹកដីខ្មែរដ៏ធំល្វឹងល្វើយនេះ បារាំងបានមកធ្វើ អាណានិគមអស់រយៈពេល៩០ឆ្នាំ ចាប់ពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ១៩៥៣ ការគ្រប់គ្រង និងការ ធ្វើអាណានិគមរបស់បារាំងនាសម័យនោះ គឺខ្មែរ កម្ពុជាក្រោម នៅមានសាលារៀនតាមភូមិស្រុក និងវត្តអារាម ការគោរពប្រពៃណីទំនៀមទម្លាប់ និងការសិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរមាន សេរីភាព និងភាពទូលំទូលាយ ថែមទាំងបាន បញ្ជូននិស្សិតខ្មែរ ដែលបានសិក្សារៀនសូត្រ បញ្ចប់ថ្នាក់នៅទឹកដីកូសាំងស៊ីន ឲ្យមកសិក្សាបន្ត នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជាទៀតផង។ ប៉ុន្តែ ចាប់ពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ ក្រោយពីបារាំងបានកាត់ទឹកដីខ្មែរឲ្យទៅវៀត ណាមរួចមក ខ្មែរកម្ពុជាក្រោមត្រូវរងគ្រោះដ៏ មហាធំធេងប្រៀបបានដូចជារលកយក្សស៊ូណា ម៉ិមកដល់ គឺវៀតណាមកាប់សម្លាប់ខ្មែរកម្ពុជា ក្រោម ដុតខ្មែរទាំងរស់ ផ្សឹកព្រះសង្ឃទៅធ្វើ ទាហាន ហាមមិនឲ្យខ្មែរបួសតាមបែបព្រះពុទ្ធ សាសនាខ្មែរទេ សាលារៀនអក្សរសាស្ត្រខ្មែរត្រូវ បិទគ្រប់ទិសទីទាំងអស់។ វៀតណាមបានបង្កើត ឲ្យមានតំបន់កុម្មុយនីស្ត និងសេរីធ្វើឲ្យខ្មែរវឹកវរ នឹងសង្គ្រាម ងាយស្រួលក្នុងការចាត់ការដូចជា គេចោទថាក្រុមកុម្មុយនីស្ត គេចាប់ខ្មែរយកទៅ ដាក់ក្នុងពន្ធនាគារ ចាក់ថ្នាំសម្លាប់ ហើយមួយ ក្រុមទៀត គេចោទថាពួកសេរី គេចាប់ខ្មែរយក ទៅបាញ់សម្លាប់ក្នុងព្រៃ និងគេបំបិទសិទ្ធិ សេរី ភាពគ្រប់បែបសព្វយ៉ាងទាំងអស់សម្រាប់ខ្មែរកម្ពុ ជាក្រោម នាបច្ចុប្បន្នកាលនេះ សូម្បីតែការមើល ទូរទស្សន៍ តាមប្រព័ន្ធខ្សែកាបនិងស្ដាប់វិទ្យុតាម ផ្កាវណប ពីព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបាន អាជ្ញាធរវៀតណាមគំរាម កំហែង និងហាមឃាត់ ជាកពិន័យ។ ដោយឡែកចំពោះសិទ្ធិសេរីភាព សិទ្ធិជនជាតិដើម និងសិទ្ធិជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ពង្សាវតាដ៏ផូរផង់ សម្បូណ៌បែបរបស់ខ្មែរត្រូវបានបំបិទទាំងស្រុង ហើយរឿងរ៉ាវទាំងអស់របស់ខ្មែរកម្ពុជាក្រោម (កូសាំងស៊ីន) នោះ វាមានច្រើនឥតគណនា ដូច លោកបារាំងធ្លាប់បានដឹងហើយ គឺខ្មែរកម្ពុជា ក្រោមវេទនាណាស់សព្វថ្ងៃនេះ។

អង្គការ សមាគមខ្មែរកម្ពុជាក្រោម សូម អំពាវនាវ និងសំណូមពរដល់ថ្នាក់ដឹកនាំជាន់ ខ្ពស់នៃសាធារណរដ្ឋបារាំង មេត្តាជួយផ្តល់ឯក សារស្តីពីការកាត់ទឹកដីកម្ពុជាក្រោម ឲ្យទៅវៀត ណាម កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ តាម ច្បាប់បារាំងលេខ ៧៣៣/៤៩ ឲ្យមកយើងខ្ញុំ តាមរយៈអាសយដ្ឋានដូចខាងលើ និងជួយ អន្តរាគមន៍ទៅរដ្ឋាភិបាលវៀតណាម ឲ្យបញ្ឈប់ ការធ្វើទុក្ខ បុកម្នេញមកលើប្រជាពលរដ្ឋខ្មែរកម្ពុ ជាក្រោម។

យើងខ្ញុំសង្ឃឹមថា ឯកឧត្តមនាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋបារាំង ច្បាស់ជាយករឿងរ៉ាវ របស់ខ្មែរកម្ពុជាក្រោម ទៅដាក់ជូនថ្នាក់ដឹកនាំ ហើយជួយធ្វើតាមសំណូមពរ ដើម្បីសិទ្ធិសេរី ភាព និងសិទ្ធិមនុស្ស នៃមនុស្សជាតិនៅលើ ពិភពលោក ហើយយើងខ្ញុំសូមជូនពរឯកឧត្តម ព្រមទាំងសហការី ឲ្យទទួលបានជោគជ័យក្នុងដំ ណើរទស្សនកិច្ច នៅក្នុងទឹកដីនៃព្រះរាជាណា ចក្រកម្ពុជា។

# ទំនៀមធ្វើស្រែនៅកម្ពុជាក្រោម (កូសាំងស៊ីន)

ដកស្រង់ទាំងស្រុងចេញពីសៀវភៅ **ទំនៀមធ្វើស្រែនៅកម្ពុជាក្រោម**

ស្រាវជ្រាវដោយ កញ្ញា គៀង ធីប៉ា (ព.ស. ២៥៥៣ គ.ស. ២០០៩)

អាចារ្យ ឱញ-ប្រាជ្ញ អាចារ្យពុទ្ធសាសនបណ្ឌិត្យ ខេត្តឃ្លាំង កម្ពុជាក្រោម (កូសាំងស៊ីនវង្វាន់លេខ១)។ អ្នកប្រទេសនេះ តែដល់ខែដើមឆ្នាំ គឺដើមខែពិសាខ កាលបើមានភ្លៀងធ្លាក់ម្ដងឬពីរដង គឺចាប់ពីផ្ដើមធ្វើស្រែ តែមុនពេលដែលចុះដៃធ្វើស្រែនោះ ជាទំនៀមរបស់អ្នកស្រុក គឺមានការឡើងអ្នកតាជាដំបូងសិន។

## អំពីរបៀបឡើងអ្នកតា

តាមទំនៀមទម្លាប់អ្នកស្រុកនោះ តែដល់ដើមខែពិសាខ អ្នកស្រុកគេតែងនាំគ្នាឡើងអ្នកតា។ ឯថ្ងៃដែលត្រូវឡើងអ្នកតានោះ គេយកដើមចេកមកកាត់១ទោម ឬ១ចំអាម ចិតចុងឲ្យស្រួច យកស្លឹកដូងមកដោតធ្វើជាជម មានអំបោះសម្រាប់ធ្វើចំណងដាក់លើជម អ្នកដែលចង់ឲ្យពូកែសក្តិសិទ្ធិមែន ក៏យកទៅបំពាក់លើថ្មអ្នកតាតែម្ដង។ របៀបបែបនេះមានគ្រប់ផ្ទះ អ្នកដែលឡើងអ្នកតា។

## អំពីគ្រឿងសំណែន

គ្រឿងសែនតាមទំនៀមនោះ គឺមានស្រាជ្រូកស្ងោរខ្លះ បើស្រុកណាទុរ្ភិក្សមានតែក្បាលជ្រូកក៏បាន ទាស្ងោរ មាន់ស្ងោរ ចេក ក្រពង[(១)] ដូងខ្ចី នំគ្រប់មុខ មាននំបញ្ចុកជាដើម នំទៀន (នំគម) នំអន្សមជ្រូក ផ្លែអាយ[(២)] និងបាយ ម្ហូបផ្សេងៗ ប្រេងម្សៅ ទឹកអប់ ទឹកតែ ទៀន ធូប និងប្រអប់ស្លា ហើយធ្វើសំពៅដើមចេកមួយ។

លុះដល់កំណត់ពេលវេលា ទៅជួបជុំគ្នានៅផ្ទះអ្នកតានោះ រៀបគ្រឿងសំណែនស្រេចហើយ គេក៏អុជទៀន ធូប បើកប្រអប់ស្រាចាក់សព្វសែនបីដង គេហៅថា សែនព្រះពិស្ណុការភ្លេង រួចលេងភ្លេងបីចប់ ក៏តាំងអុជទៀនធូបម្ដងទៀត ដាក់ទៅលើអ្នកតា ហើយចាក់ស្រាសែនចំពោះអ្នកតាបីដង យកស្រាស្រោចលើអ្នកតានោះ ហើយគេក៏ចាប់បាយម្ហូប ក្បាលជ្រូកក្បាលទា ក្បាលមាន់ និងនំគ្រប់មុខដាក់ក្នុងសំពៅសែនម្ដងទៀត ហើយមនុស្សចាស់ៗឲ្យពរជ័យសួរស្ដី សុខចម្រើន ហើយក៏ស្រែកហ៊ោព្រមគ្នាគឹកកងឡើង។ តទៅនេះ គេនាំគ្នាជូនសំពៅទៅឆ្ងាយបន្តិច ក៏ដាក់ចោលក្នុងទីនោះទៅ នេះសន្មតថា ជូនខ្មោចបិសាចចង្រៃឲ្យទៅឲ្យផុតអំពីភូមិស្រុក រួចហើយគេនាំគ្នាបរិភោគបាយចំណីតាមកាលវេលាទៅ។ លំដាប់នោះគេក៏សូមចំណងដែលដាក់លើជម ឬលើថ្មអ្នកតានោះ តែរៀងៗខ្លួនដល់បានអម្បោះនោះ គេមកយកទៅផ្ទះចងតកូនចៅ គោក្របីតាមត្រូវការនេះជាទំនៀមទម្លាប់របស់ស្រុក ពីបុរាណរៀង

(១) ក្រពង គឺឈ្មោះចំណីមួយយ៉ាង គេយកអំបុកស្រូវដំណើបទៅលីងបំពងហើយនឹងទឹកស្ករពូតជាដំមូលៈ នំក្រពង។

(២) ផ្លែអាយ គឺជានំបំពួនស្ករ។ ចាស់ៗដំណាលប្រាប់ថា នំបំពួកស្ករនេះឈ្មោះថា នំផ្លែអាយផងដែរ។

មក។ រឿងឡើងអ្នកតានេះ ខ្ញុំបាទបានដឹង ឮ ដោយខ្លួនឯងផង ដោយបានឃើញតម្រារបស់លោកគ្រូអាចារ្យ **ថាច់ ប៉ាង** តែងទុកក្នុងក្រសួងពុទ្ធសាសនបណ្ឌិតរង ប្រចាំដែនកូសាំងស៊ីន កម្ពុជាក្រោម។

## អំពីជំនឿនៃការឡើងអ្នកតា

គឺគិតឃើញថា តែបានធ្វើដូច្នេះហើយ អ្នកតាអាចប្រសិទ្ធិពរឲ្យមនុស្ស និងសត្វទាំងអស់ឲ្យបានសេចក្ដីសុខ ចម្រើន។ មិនតែប៉ុណ្ណោះជឿជាក់ថា អ្នកតានោះអាចបណ្ដាលឲ្យទឹកភ្លៀងធ្លាក់មកត្រូវតាមរដូវកាល ដើម្បីងាយដល់ការធ្វើស្រែចំការ។ ប៉ុន្តែការឡើងអ្នកតានេះ តាំងពីព្រះរាជបណ្ណាល័យ បានឧប្បត្តិកើតឡើងក្នុងកម្ពុជរដ្ឋ ហើយបានផ្សាយអារ្យធម៌ ឬផ្សាយរស្មីទៅដល់ពេលណា ការគោរពបូជាអ្នកតា ក៏កាន់តែសាបសូន្យទៅបន្តិចម្ដងៗ រហូតដល់សព្វថ្ងៃនេះ ក៏នៅមានអ្នកគោរពរាប់អានដោយស្ទាក់ស្ទើរ ឬដោយអៀនអន់ មិនបានធ្វើទៅដោយពេញជំនឿដូចពេលមុនៗនោះឡើយ។

បន្ទាប់អំពីការឡើងអ្នកតានេះ ខ្ញុំនឹងរៀបរាប់អំពីការធ្វើស្រែជាលំដាប់តទៅ។ ការធ្វើស្រែនេះ ត្រូវអាស្រ័យដោយប្រដាប់សម្រាប់ធ្វើនោះជាច្រើនគឺ ប្រដាប់សម្រាប់ធ្វើក្នុងរដូវភ្លៀង និងប្រដាប់សម្រាប់ធ្វើក្នុងរដូវរាំងហើយ។

## ប្រដាប់សម្រាប់ធ្វើស្រែក្នុងរដូវភ្លៀង

| | |
|---|---|
| ១. នង្គ័ល | ២. រនាស់ |
| ៣. ថ្លុក | ៤. ដាវ |
| ៥. ទំពក់ | ៦. គ្រាំគ្រា |
| ៧. ជ្រោង | ៨. ដើងម៉ា (តាំង) |
| ៩. ដងធក់ | ១០. ឈើរែក |
| ១១. ក្ដារដឹក | ១២. ឈើកុង |
| ១៣. ឈើប្រាន។ | |

*សម្ភារៈដែលប្រើដោយកម្លាំងគោ ក្របីគឺៈ*

- នង្គ័លសម្រាប់ភ្ជួរដី
- រនាស់សម្រាប់រាស់ឲ្យបែកដី និងរំលើងដើមស្មៅ
- ថ្លុកសម្រាប់វាយឲ្យបែកដី និងបង្កប់ដើមស្មៅ។

ថ្លុកនេះ គេយកឈើមុខទំហំ២តឹក បណ្ដោយចំនួន៣ម៉ែត្រ គេយកមកលត់ធ្វើជាស្នឹ ដូចជាផ្លែស្នឹ ដូច្នោះមាន៦ស្នឹ ហើយធ្វើជាពន្លួញមូល នៅចុងទាំងសងខាង ហើយយកឈើមួយសំប៉ែតចំនួនមួយតឹកកន្លះ កម្រាស់ចំនួន៨ហ៊ុន បណ្ដោយប្រវែង៥តឹក ដាក់ត្រណាប់២ ត្រណាប់១ក្រោមជាប់ចូលសម្រាប់ស៊កពន្លួញថ្លុក ត្រណាប់លើជាប់ជ្រុងសម្រាប់ស៊កពន្លួញធ្នឹមថ្លុក ឈើនេះធ្វើជាត្រចៀកទាំងសងខាង ចំណែកឈើដែលធ្វើធ្នឹមនោះត្រូវរកឈើឲ្យមាំបន្តិច ព្រោះនៅមានដងយកមកបោះភ្ជាប់នឹងធ្នឹមនោះទៀត។ ហើយពេលដែលបរថ្លុកនេះទៅ ខ្លួនថ្លុកនោះវារលាក់ប៉ប៉ាក់ប៉ប៉ុក ណាស់ បើធ្នឹមមិនមាំក្រែងបាក់។

**ប្រដាប់ សម្រាប់ធ្វើដោយកម្លាំងមនុស្ស មាន៖**

- ដាវសម្រាប់កាប់ ឬត្រាយស្មៅ
- តម្កក់សម្រាប់ខ្វារស្មៅ ដែលកាប់ ឬត្រាយដាច់ហើយ។ តម្កក់នេះពីដើមគេនិយមធ្វើដោយឈើ ឥឡូវគេច្រើនយកដែកមកពត់ធ្វើជាតម្កក់វិញ ព្រោះដែកប្រើជាប់មាំល្អក្រុបាក់។

## ជ្រោង

*ជ្រោងនោះត្រូវមាន២គឺ* ៖ គេយកឈើមានជំពាមពីរ ដងប្រវែងមួយម៉ែត្រ ហើយគេសម្រួចគល់ឲ្យស្រួច ជំពាមនោះទុកវែងចំនួន៤តឹក ពេលដកសំណាប គែយកទៅដោតទន្ទឹមចំនួនមួយចំអាមពីគ្នា គឺល្មមតែយកសំណាបដែលដកហើយមកដាក់ពីលើកុំឲ្យវាជ្រុះ តែសម័យសព្វថ្ងៃនេះ គេច្រើនដកនឹងជើងម៉ាជំនួសជ្រោងវិញ។

## ជើងម៉ា

ជើងម៉ានេះ គេយកក្តារស្តើងទទឹងប្រហែល៤តឹក បណ្តោយប្រវែង១ម៉ែត្រ មានជើងដូចជើងធម្មតា ប៉ុន្តែជើងនោះខ្ពស់ចំនួនមួយម៉ែត្រដូចជ្រោងដែរ។ ពេលដកសំណាបគេដករួចយកទៅលាងទឹក ហើយយកមកដាក់លើជើងម៉ា ហើយយកចំណងមកចងចុងសំណាប។ នឹងមានអធិប្បាយតទៅខាងមុខដោយច្បាស់លាស់។

## ដងឆក់

ដងឆក់នោះមានទ្រង់ទ្រាយដូចនេះ គឺគេយកឫស្សីទំហំប៉ុនកំភួនដៃខ្លះ ពុះជាពីរក៏មានខ្លះទុកទាំងមូលក៏មាន ហើយសម្រួចចុងដើមទាំងសងខាងឲ្យស្រួច។ ដងឆក់នេះគេសម្រាប់យកទៅរែកសំណាបដែលចងជាកណ្តាប់ហើយនោះ។ គេយកចុងដែលសម្រួចនោះទៅដោកតនឹងកណ្តាប់ម្ខាងមួយកណ្តាប់ ឬពីរកណ្តាប់តាមកម្លាំងដែលរែកបាន រួចយកទៅដាក់ក្នុងស្រែសម្រាប់ឲ្យគេស្ទូង។

## ឈើរែក

ឈើរែកនេះ គេយកឫស្សីចំនួនធំជាងកំភួនដៃ បណ្តោយប្រវែង៣ម៉ែត្រខ្លះ។ ឈើរែកនេះ ក៏សម្រាប់រែកសំណាបដូចដងឆក់ដែរ។ ប៉ុន្តែឈើរែកនេះ មានចន្ទល់ពីរសម្រាប់ៗទល់ចងដើមដង។ ឈើចន្ទល់នោះ គេច្រើនយកគល់ឫស្សីណាដែលក្រាស់ៗមកធ្វើ គឺយកគល់ឫស្សីវែង ប្រវែងមួយម៉ែត្រ ២តឹក មកពុះជាពីរសម្រួចគល់ឲ្យស្រួច ហើយឆែកក្បាលម្ខាងឲ្យមានជាចំពាមបន្តិច ដើម្បីដាក់ឈើរែកពីលើកុំឲ្យធ្លាក់ ឈើរែកនេះរែកសំណាបបានច្រើនជាងដងឆក់។ ពេលរែក គេយកចន្ទល់ទាំងពីរទៅដោតពីលើ ហើយយកកណ្តាប់សំណាបទៅបំពាក់លើឈើរែក ៦-៨-១០-១២ តាមកម្លាំងដែលរែករួច។ ឈើរែកនេះ បើសិនណាមិនមានចន្ទល់ទេ ដក់ផ្ទាល់នឹងដីតែម្តង ហើយយកសំណាបមកបំពាក់ ដល់ឃើងលើករែក លើកពុំរួច ព្រោះធ្ងន់ពេក ហេតុហ្នឹងត្រូវបានចន្ទល់ទុកសម្រាប់ទល់ ដល់ពេលណារែក ស្រាប់តែយកស្មាចូលកើបរែកទៅតែម្តង។

**(នៅមានត)**

# ការចាប់លោក ចៅ ហេន ញាត់គុក ជាចន្លុះឆ្លើងដុតបេះដូងខ្មែរក្រោម

លោក ចៅ ហេន ត្រូវបានរដ្ឋាភិបាលបក្សកុម្មុយនីស្តវៀតណាម ប្រកាសសាលក្រមកាល ពីថ្ងៃទី៣១ ខែមីនា ម្សិលមិញនេះ ឲ្យជាប់ពន្ធនាគារ២ឆ្នាំ ពីបទអ្វីមួយដែលបក្សកុម្មុយនិស្តយួនចោទថាបាន «បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបង្កឲ្យមានភាពចលាចលនៅទី សាធារណៈ» ក្រោយពីនគរបាលយួនបានចាប់ខ្លួនគាត់ (លោក ចៅ ហេន) ញាត់គុក អស់រយៈពេលជាង ៣ ខែកន្លងមក ។ វាមានយុត្តិធម៌ដែរឬទេ សម្រាប់អ្វីដែលរដ្ឋាភិបាលវៀតណាមតែងតែបានឃោសនាអះអាងថា ខ្លួនជានិច្ចកាលយកចិត្តទុកដាក់ដល់បញ្ហា ជីវភាពនៃការរស់នៅរបស់ជនជាតិភាគតិចទាំង៥៤ នៅក្នុងប្រទេស ក្នុងនោះមានពលរដ្ឋជនជាតិដើមខ្មែរក្រោមផងដែរ តែដោយគ្រាន់តែ លោក ចៅ ហេន ធ្វើការទាមទារដី កេរដូនតាដែលត្រូវបានរដ្ឋាភិបាលវៀតណាមបានរឹបយកប៉ុណ្ណោះ ក៏អាជ្ញាធរវៀតណាម ចាប់ញាត់ចូលគុកទៅហើយ។ នេះជាសកម្មភាពមួយមិនត្រឹមតែវៀតណាមមិនបានធ្វើ តាមគោលនយោបាយដែលខ្លួនបានឃោសនាប៉ុណ្ណោះទេ វាថែមទាំងបានជិះជាន់និង ធ្វើទុក្ខបុកម្នេញជនជាតិដើមម្ចាស់ស្រុកទាំងភ្នែកស្រស់ទៀតផង ។

លោក ចៅ ហេន (Châu Hên) កើតឆ្នាំ ១៩៥៤ នៅក្រុមទី ១ ភូមិអាងឡើយ ឃុំចៅឡាំង ស្រុកស្វាយទង ខេត្តមាត់ជ្រូក ( Tổ I ấp An Lợi xã Châu Lăng huyện Tri Tôn tỉnh An Giang ) ជាអ្នកដឹកនាំកសិករខ្មែរក្រោមនៅខេត្តមាត់ជ្រូកជាច្រើនគ្រួសារធ្វើការប្ដឹងទៅ អាជ្ញាធរវៀតណាមពីថ្នាក់មូលដ្ឋានទៅថ្នាក់មជ្ឈិម ពីខេត្តមួយទៅខេត្តមួយ ដើម្បីទាមទារយកដីស្រែកេរដូនតាមកវិញ ក្រោយពីអាជ្ញាធរបក្សកុម្មុយនិស្តបានយកដីកេរដូនតា របស់ពួកគាត់ទៅចែកឲ្យជនជាតិយួនគ្នាគេ កាលពីឆ្នាំ១៩៧៨ ខណៈដែលពួកគាត់ត្រូវ បានអាជ្ញាធរវៀតណាមជម្លៀសចេញឲ្យទៅនៅខេត្តឃ្លាំង និងខេត្តផ្សេងៗទៀតក្នុង គោលបំណងអ្វីមួយដែលរដ្ឋាភិបាលវៀតណាមកាលណោះបានអះអាងថា គេចចេញពីការចូលឈ្លានពាន របស់កងទ័ពខ្មែរក្រហមនៅតាមបណ្ដោយព្រំដែនកម្ពុជាវៀតណាម (កម្ពុជាក្រោម)។ ក្រោយពីការជម្លៀស ពួកគាត់បានត្រឡប់មកស្រុកកំណើតវិញ ក៏ស្រាប់តែដីកេរដូនតារបស់ខ្លួន ត្រូវបានយួនយកអស់រហូតមកដល់ពេលនេះ។ អាជ្ញាធរវៀតណាមកាន់ជើងជនជាតិយួនរបស់ខ្លួន មិនបានធ្វើការដោះស្រាយ និងរកយុត្តិធម៌ជូនពលរដ្ឋខ្មែរក្រោមម្ចាស់ដីឡើយ។

ករណីការធ្វើបាតុកម្មទាមទារដីកេរដូនតារបស់ក្រុមពលរដ្ឋខ្មែរក្រោម នៅខេត្តមាត់ជ្រូកនេះ បានអូសបន្លាយជាច្រើនឆ្នាំមកហើយតែ



លោក ថៅ ហេន

មិនមានលទ្ធផលឡើយ។ លទ្ធផលនៃការតវ៉ានេះត្រូវទទួលបញ្ច្រាសទិសវិញ គឺអ្នកដែលធ្វើការទាមទារត្រូវបានអាជ្ញាធរយួន តាមដានធ្វើទុក្ខបុកម្នេញ វាយដំច្រំធាក់ និងចាប់ដាក់គុកជាដើម។ ជនរងគ្រោះទាំងនោះរួមមានអ្នកស្រី នាង យ៉ូន និង នាង យ៉ន ត្រូវបានតុលាការប្រជាជនយួន កាត់ទោសកាលពីឆ្នាំ ២០០៨ ឲ្យជាប់គុក ២ ឆ្នាំ កញ្ញា នាង សាវង្ស កូនស្រីរបស់លោក ថៅ អិន ត្រូវនគរបាលយួនធ្វើទារុណកម្មរហូតដល់ស្លាប់កាលពីថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១០ គ្រួសារ លោក ថៅ អុក បានភៀសខ្លួនទៅប្រទេសកម្ពុជានិងឡើង ទៅសុំសិទ្ធិជ្រកកោន នៅការិយាល័យអគ្គស្នងការអង្គការសហប្រជាជាតិទទួលជនភៀសខ្លួន (UNHCR) ប្រចាំទីក្រុងបឹងកក់ ប្រទេសថៃ រួមជាមួយនឹងគ្រួសារលោក ថៅ ហេន ជាដើម ។

យោងតាមដីកាចាប់ខ្លួនលោក ថៅ ហេន មួយច្បាប់ចេញថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០១០ ដោយការិយាល័យនគរបាលយួនស្រុកស្វាយទង បានចោទប្រកាន់ លោក ថៅ ហេន ថា បាន « បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ (សាធារណៈ) និងបង្កភាពចលាចលក្នុងទីសាធា រណៈ » ( Hủy họai tài sản - Gây rối trật tự công cộng ) តាមមាត្រាទី ១៤៣ និង២៤៥ នៃច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសសាធារណរដ្ឋសង្គមនិយមវៀតណាម។ ការចាប់ខ្លួនលោក ថៅ ហេន នេះ បន្ទាប់លោកនិងប្រពន្ធឈ្មោះ នាង ជួន បានធ្វើគេហនិវត្តពីប្រទេសថៃទៅកាន់ផ្ទះរបស់ខ្លួនវិញនៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១០ កន្លងទៅនេះ ក្រោយពីអង្គការ UNHCR បដិសេធឋានៈជាជនភៀសខ្លួនរបស់គាត់ ហើយមន្ត្រីការិយាល័យ UNHCR បានបញ្ជាក់ប្រាប់គាត់ថា គ្រួសារលោក ថៅ ហេន អាចធ្វើដំណើរ ត្រឡប់ទៅស្រុកកំណើតវិញបានដោយអាជ្ញាធរយួនមិនធ្វើទុកបុកម្នេញឡើយ ។

ករណីនេះបញ្ជាក់ឲ្យឃើញថា វៀតណាម នៅតែមានការរើសអើងពូជសាសន៍ចំពោះជនជាតិដើមខ្មែរក្រោម នៃដែនដីកម្ពុជាក្រោមដដែល ខណៈដែលខ្លួនជាប្រទេសមួយបានចុះហត្ថលេខាគាំទ្រ ចំពោះការអនុម័តដោយសេចក្តីសម្រេច របស់មហាសន្និបាត លេខ ៦១/២៩៥ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧ នៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម។ ទង្វើរំលោភសិទ្ធិមនុស្ស និងការជិះជាន់បែបអាណានិគមពីសំណាក់អាជ្ញាធរវៀតណាម ទៅលើពលរដ្ឋខ្មែរក្រោមម្ចាស់ដីនេះ មិនមែនជាមធ្យោបាយមួយ សម្រាប់ការអភិវឌ្ឍប្រទេស

តទៅទំព័រ៣២

# ខ្មែរឡើងទ្រើង

វស្សាភ្លៀងធ្លាក់ចាក់ជោកដី
ស្មានថាប្រពាយអន្លក់ស្រស់

ខ្មែរផុះផុតដីពន្លកលាស់
ធ្វើទ្រើងឲ្យបោះពួយរលិថ្លៃ ។

ថែទាំថ្នមថ្នាក់ចាក់ស្រោចទឹក
បន្លែខ្ចីស្រស់ផ្លែប្រពាយ

ក្នុងចិត្តគិតនឹកនឹងបានឆី
បីបាច់រាល់ថ្ងៃក្នុងចម្ការ ។

ខែប្រាំងឈានមកពន្លកខ្មែរ
សប្បាយចិត្តហួសព្រោះគិតថា

បញ្ចេញផ្កាផ្លែដូចប្រាថ្នា
ជិតបានពិសាផលាស្រស់ ។

ដល់ពេលកំណត់ខ្មែរទុំជោរ
នាំយកមមីសខ្មែររមាស់

ព្រះពាយផាត់មកគ្មានស្រណោះ
រោលមនុស្សស្រីប្រុសក្តៅក្រហាយ ៕

ថ្ងៃព្រហស្បត៏ ៧ រោច ខែជេស្ឋ ឆ្នាំថោះត្រីស័ក ព.ស.២៥៥៥ (២៣ មិថុនា ២០១១)
និពន្ធដោយៈ ថាច់ ប្រីជា គឿន/Preynokor News

---

# យួនឆ្នាស

ពាក្យថាយួនមានន័យអាក្រក់ណាស់
ខួរក្បាលកើតមកគិតតែលួចប្លន់

ខ្មែរក្រោមស្គាល់ច្បាស់ចរិតចោកអន់
ដើរសាងអាសន្នឲ្យគេឲ្យរងរ ។

យួនប្រែថាចោរណាអស់ប្រុសស្រី
យកដីខ្មែរក្រោមធ្វើទ្រព្យខ្លួនឯង

ចូលមកប្លន់ដីដុតផ្ទះសម្បែង
វាយប្ញកខែងរែងថាខ្លួនជាម្ចាស់ ។

កាប់ចាក់សម្លាប់ខ្មែរក្រោមរាប់លាន
ខ្មែរក្រោមតូចធំស្គាល់ពុតយួនច្បាស់

ចិត្តចោរឈ្លានពានឥតមានកេរ្តិ៍ខ្មាស
ចោរយួនបោកប្រាស់ខ្មែរអើយត្រូវចាំ ។

ខ្មែរលើកណ្តាលរួមទាំងខ្មែរក្រោម
រំដោះខ្មែរយើងឲ្យផុតគុកកម្ម

សាមគ្គីព្រៀងព្រមកុំឲ្យប្រេះស្រាំ
មិនដល់រយឆ្នាំខ្មែររួចទុក្ខហើយ ៕

សហរដ្ឋអាមេរិកថ្ងៃ ១២ ខែមិថុនា ឆ្នាំ ២០១១
ដោយៈ ថាច់ បុរី /VOKK

**តពីទំព័រ៣០** របស់ខ្លួនឡើយ។ រដ្ឋាភិបាលបក្សកុម្មុយនិស្តវៀតណាមធ្វើបែបនេះ វាមិនខុសពីខ្លួនបានបង្កើតចន្លុះភ្លើងមួយសម្រាប់ដុតបេះដូងខ្មែរក្រោម ដែលកំពុងតែនៅក្តៅធំ ដោយកំហឹងនៃប្រវត្តិសាស្ត្រ «កុំរើប្រយ៉ាត្នកំពុបតែអុង» ឲ្យឆាបឆេះឡើងជាថ្មីម្តងទៀត នៅកម្ពុជាក្រោម ឡើយ។ សម្រាប់អង្គការ UNHCR ប្រចាំប្រទេសថៃវិញ ជាអង្គការមនុស្សធម៌ពិភពលោក តែវាហាក់ដូចជាមិនបានបំពេញការងារឲ្យបានត្រឹមត្រូវតាមតួនាទីរបស់ខ្លួនទេ។ក្នុងនាមជាអង្គការសហប្រជាជាតិមួយ តែមិនបានស្វែងយល់ឲ្យបានច្បាស់ អំពីពុតត្បុតរបស់កុម្មុយនិស្តយួនឡើយ ហើយហ៊ានបញ្ជាឲ្យ លោក ថៅ ហេនត្រឡប់ទៅស្រុកចូលគុកយ៉ាងនេះ? ចំពោះពលរដ្ឋខ្មែរក្រោមនៅក្រៅប្រទេសវិញ ពេលនេះគួរតែនាំគ្នាធ្វើអ្វីមួយ សម្រាប់ជួយដល់លោក ថៅ ហេន និងជនរងគ្រោះឯទៀតដែលកំពុងតែជាប់គុកនៅកម្ពុជាក្រោមហើយ ដោយយើងអាចធ្វើញត្តិប្តឹងទៅគ្រប់អង្គការជាតិ និងអន្តរជាតិនានា និងធ្វើបាតុកម្មនៅមុខស្ថានទូតយួន នៅតាមប្រទេសដែលអស់លោកកំពុងរស់នៅ ដើម្បីជម្រុញឲ្យអាជ្ញាធរយួនដោះលែងលោក ថៅ ហេន ជាបន្ទាន់៕

ដោយ៖ **ថាច់ ប្រីជា គៀន/preynokor News**

---

**តពីទំព័រ៩** ក្រោមផ្ទាល់ នាងបានលើកបញ្ហាជាច្រើនដូច្នេះថា "សហគមន៍មិនសូវមានការសាមគ្គី ការនេសាទខុសច្បាប់ គ្រឿងញៀន ករណីក្មេងទំនើង ចាំ! ហើយមានបញ្ហាជាច្រើនទៀត ជាពិសេស បើនៅខេត្តកំពង់ស្ពឺគឺបញ្ហាដីធ្លីជាមួយក្រុមហ៊ុន។ ហើយប្រជាពលរដ្ឋនៅខាងខេត្តបាត់ដំបង ខេត្តកណ្តាល ខ្មែរកម្ពុជាក្រោមហ្នឹងគាត់រស់នៅលើសំណង់ ទំនប់អាណាធិបតេយ្យរបស់រដ្ឋ។ ចឹងគាត់ប្រឈមមុខខ្ពស់នៅពេលដែលថ្ងៃក្រោយ ពេលដែលគាត់ចេញទៅ គាត់មិនមានអីសម្រាប់សំអាងដើម្បីបញ្ជាក់ ព្រោះគាត់អត់ទាន់មានអត្តសញ្ញាណប័ណ្ណទេ។ ប្រជាពលរដ្ឋនៅដំបន់ហ្នឹងគាត់អត់មានអត្តសញ្ញាណប័ណ្ណ ចឹងកាលណាដែលគាត់ចេញពីអាងទំនប់ហ្នឹងទៅ មិនដឹងថាគាត់មានអីជាសំអាងទៀតទេ ហើយសមាគមយើងកំពុងតែធ្វើអន្តរាគមន៍ទៅលើផ្នែកហ្នឹងដែរ" កញ្ញា **ផន ឈុនលី** តាំងចិត្តថា យកចំណេះដឹងផ្នែកច្បាប់នេះទៅអនុវត្តការងារ ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

ថ្លែងក្នុងកិច្ចបិទអង្គសិក្ខាសាលានោះដែរ លោក **យ៉ា ណេត** មន្ត្រីកម្មវិធីនៃអង្គការ Diakonia សំដែងការលើកទឹកចិត្តដល់ សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ ក្នុងការស្វែងរកជំនួយពីអង្គការ Diakonia ទៅលើកម្មវិធីចំនួន៣គឺ ច្បាប់ តស៊ូមតិ និងយែនឌ័រ ដែលជាកម្មវិធីចំបងរបស់លោក៕

ដោយ ÷ **គឹម បុរី** /UKKBS